00573292

E187

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 07 / 2010
ម៉ោង (Time/Heure): 12 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 07 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent charge du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧/អវតក/អជសដ
Case File/ Dossier N° 001/18-07-2007/ECCC/TC

នៅចំពោះមុខ : ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

កាលបរិច្ឆេទ : ថ្ងៃទី២៦ ខែកក្កដា ២០១០

ចំណាត់ថ្នាក់ : សាធារណៈ

---

# សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ៖**
កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Phillipe CANONNE
ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN
Fabienne TRUSSES-NAPROUS
Christine MARTINEAU

**សហមេធាវីការពារក្តី៖**
ការ សាវុត្ថ
François ROUX
Marie-Paule CANIZARÈS

## I. សេចក្ដីផ្ដើម

១. នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ មេធាវីការពារក្ដីបានដាក់អញ្ញត្រកម្មមួយទាក់ទងទៅនឹងការរលត់បណ្ដឹងអាជ្ញា ចំពោះបទឧក្រិដ្ឋដែលបានចោទប្រកាន់តាមច្បាប់ជាតិ ដោយស្នើសុំឱ្យបដិសេធបទចោទប្រកាន់នានាលើជនជាប់ចោទ ដោយផ្អែកតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៃព្រះរាជាណាចក្រកម្ពុជា (ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦)[១]។ បណ្ដឹងទាក់ទងនឹងអញ្ញត្រកម្មលើកឡើងថា បទឧក្រិដ្ឋតាមច្បាប់ជាតិ ដែលចោទប្រកាន់ចំពោះជនជាប់ចោទ ស្ថិតនៅក្នុងដែនកំណត់នៃអាជ្ញាយុកាលដែលអាចអនុវត្ត ហើយឧក្រិដ្ឋកម្មតាមច្បាប់ជាតិទាំងនោះបានផុតរលត់ថិរវេលានៃអាជ្ញាយុកាលទៅហើយ[២]។ មេធាវីការពារក្ដីបានលើកឡើងថា ដោយសារតែអាជ្ញាយុកាលបានផុតរលត់ មុនការពន្យារថិរវេលានៃអាជ្ញាយុកាល ដោយមាត្រា៣ថ្មី នៃច្បាប់ អ.វ.ត.ក[៣] ដូចនេះ បទប្បញ្ញត្តិនៃការពន្យារថិរវេលាអាជ្ញាយុកាលរំលោភលើគោលការណ៍អប្រតិសកម្ម[៤]។

២. អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា បណ្ដឹងអំពីអញ្ញត្រកម្មអាចទទួលយកបាន ហើយនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានណែនាំភាគីនានាឱ្យដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឆ្លើយតបទៅនឹងអញ្ញត្រកម្ម ដោយបានលើកឡើងនូវសំណួរដូចខាងក្រោមនេះ[៥]៖

១. តើការបំពេញកិច្ចការតាមផ្លូវច្បាប់ណាមួយ ដូចជា ការចោទប្រកាន់ ឬការស៊ើបសួរ ឬកាលៈទេសៈនៃអង្គហេតុណាមួយ ដូចជា ប្រព័ន្ធតុលាការ

---

[១] ប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៥៥ ដោយព្រះមហាក្សត្រ (ក្រមលេខ ៩៣៣ NS) ព្រះរាជាណាចក្រកម្ពុជា *Recueil Judiciaire* បោះពុម្ពពិសេស ឆ្នាំ១៩៥៦ ទំព័រ១១-៤០៣។

[២] "អញ្ញត្រកម្មទាក់ទងនឹងការរលត់បណ្ដឹងអាជ្ញាដែលបានចោទប្រកាន់ពីបទឧក្រិដ្ឋតាមច្បាប់ជាតិ" ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E9/1 ("អញ្ញត្រកម្ម")។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ ៦-៨។

[៣] "ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដោយមានបញ្ចូលនូវវិសោធនកម្ម ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (NS/RKM/1004/006)។

[៤] អញ្ញត្រកម្ម កថាខណ្ឌ ៥-៧។

[៥] "សេចក្ដីណែនាំស្នើសុំឱ្យដាក់សារណាជាលាយលក្ខណ៍អក្សរស្ដីពីអញ្ញត្រកម្ម" ឯកសារ E9/4 ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩។ ប្រតិចារឹក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ ៧។

ដែលមិនដំណើរការមួយរយៈ បានផ្អាច់ ឬព្យួរអាជ្ញាយុកាលដែលគ្របដណ្ដប់លើបទឧក្រិដ្ឋតាមច្បាប់ជាតិ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីជនជាប់ចោទដែរឬទេ?

២. តើថិរវេលានៃអាជ្ញាយុកាលដែលគ្របដណ្ដប់លើបទល្មើសដែលបានលើកឡើងខាងលើ ផុតរលត់បណ្ដឹងអាជ្ញាក្នុងការចោទប្រកាន់ជនជាប់ចោទ មុនការប្រកាសឱ្យប្រើ មាត្រា៣ និងមាត្រា៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ និងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ដែរឬទេ? ប្រសិនបើថិរវេលានៃអាជ្ញាយុកាលផុតរលត់ តើបទប្បញ្ញត្តិទាំងនោះមានចែងអំពីការបង្កើតឱ្យមានឡើងវិញ និងការដាក់ឱ្យមានដំណើរការឡើងវិញនូវសិទ្ធិក្នុងការចោទប្រកាន់ដែរឬទេ?

៣. តើការពន្យារថិរវេលានៃអាជ្ញាយុកាល ដែលមានចែងក្នុងមាត្រា៣ និងមាត្រា៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ "ច្បាប់ អ.វ.ត.ក" គឺជាបទប្បញ្ញត្តិនីតិវិធី ឬជាបទប្បញ្ញត្តិសារធាតុ? ប្រសិនបើបទប្បញ្ញត្តិនេះជាច្បាប់នីតិវិធី តើវានឹងមានផលវិបាកផ្នែកច្បាប់អ្វីខ្លះ? ឬប្រសិនបើជាបទប្បញ្ញត្តិសារធាតុ តើវានឹងមានផលវិបាកផ្នែកច្បាប់អ្វីខ្លះ?

៤. ប្រសិនបើបទប្បញ្ញត្តិនេះត្រូវបានចាត់ទុកថាជាបទប្បញ្ញត្តិនីតិវិធី តើច្បាប់បង្កើត អ.វ.ត.ក មានចែងអំពីការយោងណាមួយទៅនឹងបទដ្ឋានអន្តរជាតិដើម្បីធ្វើមោឃភាពអានុភាព ចំពោះបទប្បញ្ញត្តិមួយរបស់ខ្លួនដែរឬទេ? ប្រសិនបើមាន តើលោកអ្នកអាចបង្ហាញអំពីបទដ្ឋានអន្តរជាតិពាក់ព័ន្ធ ដែលគួរយកមកអនុវត្តបានដែរ ឬទេ?

៥. ប្រសិនបើអានុភាពគតិយុត្តិនៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ មានមកលើ អ.វ.ត.ក តើអានុភាពគតិយុត្តិទាំងនោះជាអ្វីខ្លះទៅ?

00573295



៣. លើកលែងតែដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៤ គ្រប់ភាគីទាំងអស់បានដាក់សារណា ប៉ុន្តែមិនបានដាក់សារណាតបបន្ថែមទៀតនោះទេ។

## II. សារណា

៤. មេធាវីការពារក្ដីបានលើកឡើងថា មាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងអំពីថិរវេលានៃអាជ្ញាយុកាល១០ឆ្នាំ ទាក់ទងនឹងបទឧក្រិដ្ឋតាមច្បាប់ជាតិ ដែលត្រូវផុតរលត់នៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៨៩។ ថិរវេលានៃអាជ្ញាយុកាលនេះ មិនបានផ្អាក់ ឬរំខានទេ។ ការជំនុំជម្រះលើបុគ្គលមួយចំនួន ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើឡើងក្នុងឆ្នាំ១៩៧៩ ហើយច្បាប់ជាច្រើនដែលប្រកាសឱ្យប្រើចាប់តាំងពីឆ្នាំ១៩៧៩ រហូតមក បង្ហាញអំពីអត្ថិភាពនៃប្រព័ន្ធតុលាការដែលដំណើរការមួយ។ មាត្រា៣៣ ថ្មី កថាខណ្ឌ១ និង២ តម្រូវឱ្យ អ.វ.ត.ក អនុវត្តយុត្តាធិការរបស់ខ្លួន អនុលោមតាមបទដ្ឋានអន្តរជាតិ ដូចមានចែងនៅក្នុងមាត្រា១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")។ មាត្រា៣ ថ្មី មិនអាចបង្កើតសាជាថ្មីនូវសិទ្ធិចោទប្រកាន់ចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិ នៅពេលដែលថិរវេលានៃអាជ្ញាយុកាលបានផុតរលត់ ដោយមិនរំលោភគោលការណ៍អប្រតិសកម្មជាសារវ័ន្តនោះ។ អាស្រ័យហេតុនេះ មាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក ចែងផ្ទុយនឹងបទដ្ឋានអន្តរជាតិ ហេតុដូច្នេះមាត្រានេះគ្មានសុពលភាពឡើយ[៦]។

៥. សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីទាំងបីក្រុម បានប្រឆាំងនឹងសារណារបស់មេធាវីការពារក្ដី ដោយពួកគេយល់ឃើញថា អាជ្ញាយុកាលដែលអាចអនុវត្តមិនបានចាប់ផ្ដើមរាប់មុនឆ្នាំ១៩៩៣ទេ។ នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ និងក្នុងអំឡុងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ ប្រព័ន្ធតុលាការកម្ពុជា មិនមានសមត្ថភាពកាត់សេចក្ដី និងមិនអាចកាត់សេចក្ដីលើបទឧក្រិដ្ឋទាំងនេះបានទេ។ ជនសង្ស័យសំខាន់ៗស្ថិតនៅក្នុងតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម និងស្ថិតនៅខាងក្រៅយុត្តាធិការរបស់សាធារណរដ្ឋ

---

[៦] "សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ស្ដីពីអញ្ញត្រកម្មលើកឡើងដោយក្រុមមេធាវីការពារក្ដី ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ឯកសារ E9/9 ("សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដី") កថាខណ្ឌ២, ៥, ២០, ២២, ២៥ និង២៨ (កត់សម្គាល់ផងដែរចំពោះគោលការណ៍ពាក់ព័ន្ធផ្សេងៗទៀតនៃភាពអាចប្រមើលមើលថាជាបទឧក្រិដ្ឋ និងការបកស្រាយច្បាប់ព្រហ្មទណ្ឌតាមន័យចង្អៀតរបស់ ដើម្បីផលប្រយោជន៍ដល់ជនជាប់ចោទ។

ប្រជាមានិតកម្ពុជាដែលក្រោយមកក្លាយជាព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ អាជ្ញាយុកាល ត្រូវចាត់ទុកថាបានផ្តាច់ ឬព្យួរមុនឆ្នាំ១៩៩៣ ហើយថិរវេលានៃការព្យួរ ឬផ្តាច់នេះ មិនត្រូវបានរាប់ទេនៅពេលគណនាពីថិរវេលានៃអាជ្ញាយុកាល។ អាស្រ័យហេតុនេះ ថិរវេលានៃអាជ្ញាយុកាល១០ឆ្នាំ កំពុងតែមាននៅឡើយ នៅពេលច្បាប់ អ.វ.ត.ក ប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ និងត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ដើម្បីពន្យារអាជ្ញាយុកាល។ អាជ្ញាយុកាលមានលក្ខណៈជាបទប្បញ្ញត្តិនីតិវិធី ហើយការពន្យារថិរវេលានៃអាជ្ញាយុកាលដោយមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក មិនត្រូវបានហាមឃាត់ដោយគោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌទេ។ បន្ថែមពីលើនេះ មាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក មិនបានចែងផ្ទុយនឹងមាត្រា១៤ និងមាត្រា១៥ នៃ ICCPR ទេ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលមានចែងនៅក្នុងមាត្រា១៤ នៃ ICCPR មានគោលបំណងទប់ស្កាត់ការពន្យារពេលដែលមិនសមស្រប ក្នុងអំឡុងពេលនៃដំណើរការនីតិវិធីជំនុំជម្រះជាក់ស្តែង ប៉ុន្តែមិនបានហាមមិនឱ្យមានការពន្យារថិរវេលានៅក្នុងចន្លោះពីពេលប្រព្រឹត្តបទល្មើស និងការដាក់ដីកាចោទប្រកាន់នោះទេ។ ចំណែកឯគោលបំណងរបស់មាត្រា១៥ នៃ ICCPR គឺដើម្បីទប់ស្កាត់មិនឱ្យមានការចោទប្រកាន់ និងផ្តន្ទាទោសចំពោះអំពើទាំងឡាយ ដែលមិនមានចែងថាជាបទឧក្រិដ្ឋ នៅពេលអំពើនោះត្រូវបានប្រព្រឹត្ត។ បទឧក្រិដ្ឋដែលត្រូវបានលើកឡើងនៅពេលនេះ (បទមនុស្សឃាត និងបទទារុណកម្ម) ត្រូវបានទទួលស្គាល់ជាសកលថាជាបទឧក្រិដ្ឋនៅឆ្នាំ១៩៧៥។ គោលការណ៍នីត្យានុកូលភាព មិនត្រូវបានរំលោភបំពានដោយសារការចោទប្រកាន់ចំពោះបទឧក្រិដ្ឋទាំងនេះទេ។ ហេតុដូច្នេះ បុគ្គលម្នាក់មិនគួរអាចឱ្យលុបថិរវេលានៃអាជ្ញាយុកាលដើម្បីរាំងការចោទប្រកាន់ចំពោះការប្រព្រឹត្តិរបស់ខ្លួននោះទេ[៧]។

---

[៧] "សេចក្តីសន្និដ្ឋានឆ្លើយតបជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មរបស់មេធាវីការពារក្តីចំពោះការអនុវត្តក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ឯកសារ E9/7 ("សេចក្តីសន្និដ្ឋាន របស់ ក.ស.ព") កថាខណ្ឌ១៤-២៦, ៣០-៣២, ៣៥-៣៦។ "សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ - ការដាក់សំអាងស្តីអំពីអញ្ញត្រកម្ម" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ឯកសារ E9/5 ("សារណារបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១") កថាខណ្ឌ៣-១៨, ២៥-២៦។ "សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ស្តីអំពីអញ្ញត្រកម្មទាក់ទងទៅនឹងការរលត់បណ្តឹងអាជ្ញា ដែលបានចោទប្រកាន់ពីបទឧក្រិដ្ឋតាមច្បាប់ជាតិ" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ឯកសារ E9/8 ("សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២") កថាខណ្ឌ៦ ១០-១៧។ "សារណាឆ្លើយតបរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ចំពោះអញ្ញត្រកម្មនៃការផុតរលត់

៦. គ្រប់ភាគីទាំងអស់យល់ស្របថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ២០០១ បានប្រកាសថា មាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក គឺស្របគ្នាជាមួយនឹងរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣[៨]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សេចក្តីសម្រេចនេះផ្តល់នូវការបង្ហាញយ៉ាងច្បាស់ថា មាត្រា៣ ថ្មី ចែងស្របតាមបទដ្ឋានអន្តរកម្ពុជា[៩]។ មេធាវីការពារក្តីយល់ឃើញថា សេចក្តីសម្រេចនេះបញ្ជាក់ត្រឹមតែថា គោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ មិនមានតម្លៃស្មើនឹងរដ្ឋធម្មនុញ្ញ ដូចនេះច្បាប់ អ.វ.ត.ក ជាពិសេសត្រង់មាត្រា៣ មិនបានចែងផ្ទុយនឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ទេ[១០]។ មេធាវីការពារក្តី និងក្រុមដើមបណ្តឹងរដ្ឋប្បវេណី បានលើកទឡ្ហីករណ៍ថា សេចក្តីសម្រេចមិនមានអានុភាពលើដំណោះស្រាយថាតើមាត្រា៣ ថ្មី ស្របតាមបទដ្ឋានអន្តរជាតិដែរឬយ៉ាងណា[១១]។

## III. សំអាងហេតុ

៧. ជនជាប់ចោទត្រូវបានចោទប្រកាន់ចំពោះបទមនុស្សឃាតគិតទុកជាមុន និងបទទារុណកម្មការបំពារបំពានលើមាត្រា៥០១ ៥០៦ និង៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលត្រូវផ្តន្ទាទោសនៅចំពោះមុខ អ.វ.ត.ក អនុលោមតាមមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក[១២]។

---

បណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាក់ទងនឹងច្បាប់ជាតិ" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ឯកសារ E9/6 ("សារណាឆ្លើយតបរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣") កថាខណ្ឌ៨-១៧, ២៣-២៦ និង២៨-២៩។

[៨] សេចក្តីសន្និដ្ឋាន របស់ ក.ស.ព កថាខណ្ឌ ២៧។ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី កថាខណ្ឌ៣០ (សេចក្តីសម្រេចគ្រាន់តែបញ្ជាក់ថា គោលការណ៍អប្រតិសកម្ម មិនមានតម្លៃធម្មនុញ្ញភាពទេ ហើយមាត្រា៣ នៃច្បាប់ អ.វ.ត.ក មិនផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ) និងកថាខណ្ឌ៣១ (លើកឡើងថាសេចក្តីសម្រេចនេះ មិនមានផលប៉ះពាល់ទាក់ទងនឹងបញ្ហានៃភាពស៊ីសង្វាក់គ្នានៃមាត្រា៣ ថ្មី ជាមួយនឹងគោលការណ៍អន្តរជាតិ)។ សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ កថាខណ្ឌ២៨។ សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ កថាខណ្ឌ២១-២២ (រិះគន់ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយសារតែមិនបានគោរពគោលការណ៍អប្រតិសកម្ម)។

[៩] សេចក្តីសន្និដ្ឋាន របស់ ក.ស.ព កថាខណ្ឌ២៨។

[១០] សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី កថាខណ្ឌ៣០ (ដកស្រង់ "សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ" 092/003/2007 ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ E9/9.5)។

[១១] សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី កថាខណ្ឌ៣១។ សារណារបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ កថាខណ្ឌ២៨។ សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ កថាខណ្ឌ២២។

[១២] "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្គេកអ៊ាវ ហៅ ឌុច" ឯកសារ D99 (សម្ងាត់) ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ដូចដែលត្រូវបានធ្វើវិសោធនកម្មដោយ "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំ ជម្រះលើ

00573298



អាស្រ័យហេតុនេះ មាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក បានផ្តល់អំណាចឲ្យ អ.វ.ត.ក កាត់សេចក្តីបន្ថែមពីលើបទឧក្រិដ្ឋអន្តរជាតិ នូវបទល្មើសជាក់លាក់មួយចំនួននៅក្នុងច្បាប់ជាតិដែលនៅមានសុពលភាព ប៉ុន្តែមិនត្រូវបានយកមកអនុវត្តនៅក្នុងអំឡុងសម័យខ្មែរក្រហមនោះទេ ។

៨. សាលដីការបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ដែលបានផ្តល់តាមសំណើរបស់សហព្រះរាជអាជ្ញា ឲ្យបន្ថែមបទចោទទាំងនេះ ទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានពិចារណាច្បាស់លាស់ អំពីផលប៉ះពាល់របស់ចិរវេលានៃអាជ្ញាយុកាលទៅលើសមត្ថកិច្ចរបស់ អ.វ.ត.ក ក្នុងការវិនិច្ឆ័យទោសបទឧក្រិដ្ឋទាំងនេះទេ។ ដើម្បីវាយតម្លៃបញ្ហានេះ អង្គជំនុំជម្រះយល់ឃើញថាមានលក្ខណៈចាំបាច់ត្រូវកំណត់៖

ក. ថាតើនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ចិរវេលានៃអាជ្ញាយុកាលដែលអាចអនុវត្តផ្អែកតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ឬផ្អែកតាមក្រមនានារបស់ប្រទេសកម្ពុជា ប្រសិនជាមាន អាចចាត់ទុកថាបានផ្អាក់ ឬព្យួរដែរឬទេ? (ហើយប្រសិនបើបានផ្អាក់ ឬព្យួរនោះ តើវាបានផ្អាក់ ឬព្យួរចាប់តាំងពីពេលណា និងរហូតដល់ពេលណា?)

ខ. តើការពន្យារចិរវេលានៃអាជ្ញាយុកាលតាមបទប្បញ្ញត្តិមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក អនុវត្តស្របជាមួយបទដ្ឋានជាតិ ឬអន្តរជាតិ (ជាពិសេស បទដ្ឋានទាំងឡាយដែលមានចែងនៅក្នុងមាត្រា១៤ និងមាត្រា១៥ នៃ ICCPR) ដែរ ឬទេ? ប្រសិនបើរកឃើញថា ចិរវេលានៃអាជ្ញាយុកាលដែលមានចែងនៅក្នុងច្បាប់ជាតិបានផុតរលត់មុនពេល "ការពន្យារចិរវេលានៃអាជ្ញាយុកាល" ផ្អែកតាមមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក តើអង្គជំនុំជម្រះអាចបកស្រាយមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក ថាជាបទប្បញ្ញត្តិដែលបង្កើតសាជាថ្មីនូវសិទ្ធិចោទប្រកាន់ចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិ ដោយស្របតាមគោលការណ៍នីត្យានុកូលភាពដែរ ឬទេ?

---

ករណី កាំង ហ្កេកអ៊ាវ ហៅ ឌុច" របស់អង្គបុរេជំនុំជម្រះ ឯកសារ D99/3/42 ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ") កថាខណ្ឌ១៥២។

## ក. ថិរវេលានៃអាជ្ញាយុកាលដែលអាចអនុវត្ត និងគ្រប់ខណ្ឌច្បាប់

៩. ដើម្បីកំណត់អំពីច្បាប់នានារបស់ប្រទេសកម្ពុជា ពាក់ព័ន្ធនឹងថិរវេលានៃអាជ្ញាយុកាលដែលអាចអនុវត្ត អង្គជំនុំជម្រះបានយោងលើបទប្បញ្ញត្តិច្បាប់កម្ពុជាជាច្រើនដែលបានលើកឡើងជាបន្តបន្ទាប់អំពីបញ្ហានេះ។

១០. មាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ កំណត់ថិរវេលានៃអាជ្ញាយុកាលចំនួន១០ឆ្នាំ ចំពោះបទឧក្រិដ្ឋ ០៥ឆ្នាំចំពោះបទមជ្ឈិម និង០១ឆ្នាំចំពោះបទលហុ។ អាជ្ញាយុកាលទាំងនេះ ចាប់ផ្ដើមរាប់ពីពេលដែលប្រព្រឹត្តបទឧក្រិដ្ឋ និងត្រូវបានផ្ដាច់ ដោយការផ្ដើមកិច្ចស៊ើបសួររបស់តុលាការ [១៣]។ ថិរវេលានៃអាជ្ញាយុកាលខាងលើមានចែងក្នុងមាត្រា៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៦៤ ដែលមាត្រានេះបានចែងយោងទៅរកថិរវេលានៃអាជ្ញាយុកាលដែលមានកំណត់ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[១៤]។

១១. មាត្រា៣០ នៃ "បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌដែលអនុវត្តនៅកម្ពុជា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២"("ច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២") ចែងថា "ថិរវេលានៃអាជ្ញាយុកាលសម្រាប់បទមជ្ឈិមមានរយៈពេល០៣ឆ្នាំ រីឯថិរវេលានៃអាជ្ញាយុកាលសម្រាប់បទឧក្រិដ្ឋមានរយៈពេល១០ឆ្នាំ។ អាជ្ញាយុកាលត្រូវចប់នៅពេលណាសកម្មភាពនីតិវិធីទាំងអស់បានសម្រេច"។ ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ("ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧") មានចែងអំពី

---

[១៣] មាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលច្បាប់ដើមជាភាសាបារាំង ត្រូវបានបកប្រែថា៖ "អ្នកណាប្រព្រឹត្តឧក្រិដ្ឋកម្មកន្លងលើសពីដប់ឆ្នាំ ទោសមជ្ឈិមលើសពីប្រាំឆ្នាំ និងលហុកម្មលើសពីដប់ពីរខែ អ្នកនោះបានរួចផុតពីមានទោសហើយ។ ឆ្នាំ និងខែទាំងនេះ ត្រូវរាប់តាមសុរិយគតិ"។ *សូមមើលផងដែរ* មាត្រា១១១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ (បង្ហាញថាថិរវេលានៃអាជ្ញាយុកាល ចាប់ផ្ដើមរាប់នៅពេលដែលមានការប្រព្រឹត្តអំពើដែលបានចោទប្រកាន់) ហើយមាត្រា១១២-១១៤ (ចែងថា កិច្ចស៊ើបសួរ និងការចោទប្រកាន់ ផ្ដាច់ថិរវេលានៃអាជ្ញាយុកាល ដែលថិរវេលានេះចាប់ផ្ដើមរាប់សាជាថ្មីចំនួន១០ឆ្នាំវិញ ក្រោយពីកិច្ចនៃការផ្ដាច់ចុងក្រោយ (នៅក្នុងករណីបទឧក្រិដ្ឋ)។

[១៤] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៦៤ មាត្រា៣៧ ចែងថា៖ "បណ្ដឹងអាជ្ញាក្នុងការអនុវត្តទោស អាចផុតរលត់ទៅបានតែ [...] តាមថិរវេលាអាជ្ញាយុកាល ដូចមានចែងក្នុងមាត្រា១០៩ និង១១១ នៃក្រមព្រហ្មទណ្ឌ"។ *សូមមើលផងដែរ ដូចដើងទំព័រខាងលើ* មាត្រា៣៨ និងមាត្រា២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៦៤ (ចែងថា បណ្ដឹងអាជ្ញាអាចត្រូវបញ្ឈប់ និងត្រូវព្យួរនៅពេលចាំបាច់ ដើម្បីឱ្យតុលាការស៊ើបសួរសម្រេចលើអញ្ញត្រកម្មសិទ្ធ)។

ចិរវេលានៃអាជ្ញាយុកាលគឺ១៥ឆ្នាំចំពោះបទឧក្រិដ្ឋ០៥ឆ្នាំ ចំពោះបទមជ្ឈិម និង០១ឆ្នាំចំពោះបទលហុ។ ក្រមនេះបានបញ្ជាក់ច្បាស់ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម មិនមានចិរវេលានៃអាជ្ញាយុកាលកំណត់ទេ [១៥]។ ក្រមនេះចែងនូវវិធានស្រដៀងគ្នាទៅនឹងបទប្បញ្ញត្តិទាំងឡាយ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ពាក់ព័ន្ធនឹងការចាប់ផ្តើមរាប់ចិរវេលានៃអាជ្ញាយុកាល និងអានុភាពផ្តាច់ចិរវេលានៃអាជ្ញាយុកាល នៅពេលមានកិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ [១៦]។

១២. ផ្អែកតាមការអានធម្មតាចំពោះមាត្រា១០៩ ដល់មាត្រា១១៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (ច្បាប់អាចនឹងត្រូវបានយកមកអនុវត្ត នៅពេលដែលប្រព្រឹត្តបទឧក្រិដ្ឋដែលចោទប្រកាន់) នៅក្នុងករណីដែលមិនមានកិច្ចស៊ើបសួរ ឬការចោទប្រកាន់ដែលផ្តាច់ចិរវេលានៃអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិ ដូច្នេះចិរវេលានៃអាជ្ញាយុកាលនឹងផុតរលត់យ៉ាងយូរបំផុតក្រោយពីរយៈពេលចោទប្រកាន់១០ឆ្នាំ បានកន្លងផុតទៅ ពោលគឺថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៨៩។ ទោះបីជាមានសំណើយ៉ាងច្បាស់របស់អង្គជំនុំជម្រះក៏ដោយ សហព្រះរាជអាជ្ញា និងភាគីផ្សេងទៀត មិនបានផ្តល់ភស្តុតាងណាមួយដែលបង្ហាញថា បទឧក្រិដ្ឋដែលចោទប្រកាន់ចំពោះជនជាប់ចោទ ត្រូវបានស៊ើបអង្កេត ឬចោទប្រកាន់ មុនកាលបរិច្ឆេទនោះទេ ហើយអង្គជំនុំជម្រះមិនបានកំណត់អត្តសញ្ញាណនៃភស្តុតាងណាមួយបែបនោះឡើយ [១៧]។ ដូច្នេះអង្គជំនុំជម្រះយល់ឃើញថា មិនមានភស្តុតាងគ្រប់គ្រាន់ដែលបង្ហាញថាចិរវេលានៃអាជ្ញាយុកាលត្រូវបានផ្តាច់ដោយការអនុវត្តមាត្រា១១២ ដល់មាត្រា ១១៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ [១៨] ទេ។

---

[១៥] មាត្រា៩ និងមាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[១៦] មាត្រា១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ចែងថា៖ "ចិរវេលានៃអាជ្ញាយុកាលត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស។ ចិរវេលានៃអាជ្ញាយុកាលត្រូវផ្តាច់នៅគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ។ ការបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗ នាំឱ្យចាប់ផ្តើមគិតចិរវេលាថ្មីនៃអាជ្ញាយុកាល អនុលោមតាមបទប្បញ្ញត្តិមាត្រា១០ នៃក្រមនេះ..."។

[១៧] "សេចក្តីណែនាំស្នើសុំឱ្យដាក់សារណាជាលាយលក្ខណ៍អក្សរស្តីពីអញ្ញត្រកម្ម" ឯកសារលេខ E9/4 ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩។

[១៨] *សូមមើល ក្រឹត្យ-ច្បាប់ លេខ០១ ស្តីអំពីការបង្កើតតុលាការប្រជាជនបដិវត្តន៍ (ខេត្ត និងរាជធានី)* (១៥ កក្កដា ១៩៨០) E9/9.3 ERN (ភាសាអង់គ្លេស) 00336567-00336569 ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៩ (បានរៀបរាប់អំពីការ

១៣. មាត្រា៣ និងមាត្រា៣ ថ្មី ដែលត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០១ និង២០០៤ ដំបូងបានបន្ថែមថិរវេលានៃអាជ្ញាយុកាល២០ឆ្នាំ និងក្រោយមកទៀត បានបន្ថែមថិរវេលានៃអាជ្ញាយុកាល៣០ឆ្នាំ។ សរុបទៅ ថិរវេលានៃអាជ្ញាយុកាលគឺ៤០ឆ្នាំ។ ជាដំបូង អង្គជំនុំជម្រះត្រូវសម្រេចថា តើថិរវេលានៃអាជ្ញាយុកាលត្រូវបានផុតរលត់ទៅហើយ ឬយ៉ាងណា នៅពេលការស៊ើបអង្កេតដោយ អ.វ.ត.ក លើជនជាប់ចោទត្រូវបានចាប់ផ្តើមនោះ។

១៤. អង្គជំនុំជម្រះបានរកឃើញថា ក្នុងចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ប្រព័ន្ធច្បាប់ ឬប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាមិនមាននោះទេ។ ហេតុដូចនេះ ការស៊ើបសួរ ឬការចោទប្រកាន់ពីបទព្រហ្មទណ្ឌ មិនអាចធ្វើឡើងបានទេនៅក្នុងអំឡុងពេលនោះ [១៩]។ ដូច្នេះអង្គជំនុំជម្រះយល់ស្របថា ថិរវេលានៃអាជ្ញាយុកាលមិនបានចាប់ផ្តើមរាប់ក្នុងអំឡុងពេលនោះឡើយ។ ប៉ុន្តែអង្គជំនុំជម្រះមិនបានឈានដល់ការឯកភាពគ្នា ថាតើថិរវេលានៃអាជ្ញាយុកាលដែលអាចអនុវត្ត ត្រូវបានព្យួរ ឬមិនបានព្យួរ ក្នុងចន្លោះឆ្នាំ១៩៧៩ និងឆ្នាំ១៩៩៣ និងថាតើរយៈពេលនេះ ត្រូវបានផុតរលត់មុនពេលដែលមាត្រា៣ និងមាត្រា៣ ថ្មី ត្រូវបានប្រកាសឱ្យប្រើដែរ ឬទេ។ មតិយោបល់ដាច់ដោយឡែករបស់យើងជាចៅក្រមកម្ពុជា (ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម ធូ មណី)និងចៅក្រមអន្តរជាតិ (ចៅក្រម Cartwright ចៅក្រម Lavergne) មានដូចខាងក្រោម៖

១. <u>មតិយោបល់របស់ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម ធូ មណី</u>

១៥. យើងចៅក្រមកម្ពុជា ពេលនេះត្រូវពិចារណាអំពី ថាតើអាជ្ញាយុកាលដែលយកមកអនុវត្ត បានចាប់ផ្តើមរាប់ក្នុងចន្លោះពីខែមករា ឆ្នាំ១៩៧៩ និងឆ្នាំ១៩៩៣ ដែរ ឬយ៉ាងណា។

១៦. ចៅក្រមកម្ពុជាកត់សម្គាល់ឃើញថា អនុលោមតាមតុលាការសិទ្ធិមនុស្សអឺរ៉ុប គោលបំណងសំខាន់ៗ របស់ថិរវេលានៃអាជ្ញាយុកាលរួមមាន "ការធានាសុវត្ថិភាពគតិយុត្តិ និងទប់ស្កាត់ការរំលោភសិទ្ធិទាំងឡាយរបស់ចុងចោទ ដែលករណីនេះអាចនាំឱ្យមានការ

---

ជំនុំជម្រះក្តីបន ប៉ុល ពត, អៀង សារី ដែលកាត់សេចក្តីចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្នុងមន្ទីរស២១ តែប៉ុណ្ណោះ ប៉ុន្តែការកាត់សេចក្តីនេះមិនទាក់ទងនឹងជនជាប់ចោទទេ)។ ដោយសារនីតិវិធីនោះបានបញ្ចប់នៅក្នុងឆ្នាំ១៩៧៩ ដូចនេះមានផលប៉ះពាល់បន្តិចបន្តួចប៉ុណ្ណោះ ដល់ការរាប់ថិរវេលានៃអាជ្ញាយុកាលដែលត្រូវអនុវត្ត។

[១៩] សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជសដ *កាំង ហ្គេកអ៊ាវ ហៅ ឌុច* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ផ្នែក ២.២.៣។

00573302



ខូចខាតដល់ចុងចោទ ប្រសិនបើតម្រូវឱ្យតុលាការសម្រេចដោយផ្អែកលើភស្តុតាងដែលមិនអាចទទួលបានពេញលេញ ដោយសារតែការកន្លងផុតទៅនៃពេលវេលា"[២០]។ បទប្បញ្ញត្តិមួយអាចត្រូវបានបកស្រាយដោយយោងទៅលើគោលបំណងរបស់វាបាន នៅពេលណាដែលបទប្បញ្ញត្តិនោះមិនមែនជាច្បាប់ព្រហ្មទណ្ឌសារធាតុ ដែលតម្រូវឱ្យគោរពគោលការណ៍នៃការបកស្រាយដោយតឹងរឹង[២១]។ នៅក្នុងច្បាប់កម្ពុជា ចិរវេលានៃអាជ្ញាយុកាល ជួនកាលមានចែងក្នុងក្រមព្រហ្មទណ្ឌ ប៉ុន្តែនាពេលថ្មីៗនេះចិរវេលានៃអាជ្ញាយុកាលត្រូវបានចែងក្នុងក្រមនីតិវិធីទៅវិញ[២២]។ ចិរវេលានៃអាជ្ញាយុកាលមិនបានផ្តល់សិទ្ធិឱ្យជនល្មើសប្រឆាំងនឹងរដ្ឋ ឬមិនបានរំលត់អំពើឧក្រិដ្ឋ បន្ទាប់ពីការផុតកំណត់ចិរវេលានៃអាជ្ញាយុកាលនោះឡើយ។ យោងតាមច្បាប់កម្ពុជា ចិរវេលានៃអាជ្ញាយុកាលរំលត់បណ្តឹងអាជ្ញា មិនមែនរំលត់អំពើឧក្រិដ្ឋដែលចោទប្រកាន់ឡើយ[២៣]។ ដូច្នេះហើយ ចិរវេលានៃអាជ្ញាយុកាលនេះ

---

[២០] រឿងក្តី *Coëme a.o.* *ទល់នឹង* ប្រទេស បែលហ្ស៊ិក សេចក្តីសម្រេចរបស់តុលាការ ECtHR (បណ្តឹងលេខ 32492/96, 32547/96, 32548/96, 33209/96, 33210/96) សេចក្តីសម្រេចរបស់តុលាការ ECtHR ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០០ ឯកសារ E9/5.2 កថាខណ្ឌ១៤៦។ សូមមើល *រឿងក្តី Stubbings a. o. តទល់នឹង ចក្រភពអង់គ្លេស* សេចក្តីសម្រេចរបស់តុលាការ ECt.HR ថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៦ របាយការណ៍ 1996-IV ទំព័រ១៥០២ - ១៥០៣ កថាខណ្ឌ៥១។ រឿងក្តី *Kononov ទល់នឹងប្រទេស ឡាតវី* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ECtHR (បណ្តឹងលេខ 36376/04) ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ (បដិសេធដោយសំអាងលើហេតុផលផ្សេងគ្នា) សេចក្តីសម្រេច លើរឿងក្តី *Kononov ទល់នឹង ប្រទេស ឡាតវី* សេចក្តីសម្រេចរបស់តុលាការ ECtHR, (បណ្តឹងលេខ 36376/04) ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨។

[២១] *សូមមើល* មាត្រា៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ មាត្រា ២២ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ *សូមមើលបន្ថែម* មតិយោបល់លើលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (បោះពុម្ពលើកទី២ ដោយ Beck) អ្នកពិនិត្យផ្ទៀងផ្ទាត់ Otto Triffterer មាត្រា២២ កថាខណ្ឌ៤៦។

[២២] ចិរវេលានៃអាជ្ញាយុកាល មានចែងនៅក្នុងមាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា៣០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២ និងមាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ការបញ្ចូលបទប្បញ្ញត្តិបែបនេះគឺជាការបង្ហាញតែប៉ុណ្ណោះ។ ឧទាហរណ៍ យុត្តិសាស្ត្រអាល្លឺម៉ង់ បានបញ្ជាក់ច្បាស់ថា ចិរវេលានៃអាជ្ញាយុកាលនៅក្នុងក្រមព្រហ្មទណ្ឌ គឺជាប្រភេទដាច់ដោយឡែកមួយ ដែលវាមិនមែនជាបទប្បញ្ញត្តិសារធាតុ ឬបទប្បញ្ញត្តិនីតិវិធីទេ)។ (តុលាការធម្មនុញ្ញរបស់ប្រទេសអាល្លឺម៉ង់ BVerfGE 25, 269 (2 BvL 15, 23/68))។

[២៣] *សូមមើល* មាត្រា១១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ "នាកាលរយៈពេល ដូចមានសម្តែងជាពិសេសខាងលើនេះបានកន្លងហួសអស់ទៅហើយ បណ្តឹងរបស់ភាគីស៊ីវិលដែលសុំសំណងបង់ខាតនោះក៏អស់ចិរវេលានៃអាជ្ញាយុកាលស្មើគ្នានឹងបណ្តឹងអាជ្ញានេះដែរ"។ សូមមើលផងដែរ មាត្រា៧ និង៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ (ដែលចែងអំពីមូលហេតុនៃការរលត់បណ្តឹងអាជ្ញា ដែលរួមបញ្ចូលទាំងការផុតចិរវេលានៃអាជ្ញាយុកាល)។

មិនមែនជាច្បាប់ព្រហ្មទណ្ឌសារធាតុឡើយ។ ចៅក្រមកម្ពុជាយល់ឃើញថា អ្នកធ្វើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានសន្មត់ថា ក្នុងអំឡុងថិរវេលា១០ឆ្នាំ នៃអាជ្ញាយុកាលនោះ គឺមានស្ថាប័នរដ្ឋដែលអាចផ្តើមធ្វើការស៊ើបអង្កេត ឬចោទប្រកាន់ប្រឆាំងនឹងជនដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋបាន។ ប៉ុន្តែ នៅពេលដែលស្ថានភាពជាសត្យានុម័តមួយបង្ហាញថា ការស៊ើបអង្កេតមិនអាចធ្វើទៅបានចំពោះជននោះ ថិរវេលានៃអាជ្ញាយុកាលមិនអាចអនុវត្តបានទេក្នុងករណីនេះ។ ចៅក្រមកម្ពុជាកត់សម្គាល់ឃើញថា ចៅក្រមអន្តរជាតិ ក៏បានយល់ស្របផងដែរថា ថិរវេលានៃអាជ្ញាយុកាលមិនត្រូវបានរាប់ទេក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដោយសារមូលហេតុគ្មានប្រព័ន្ធយុត្តិធម៌[២៤]។

១៧. បន្ថែមលើនេះទៀត ការអនុវត្តជាក់ស្តែងនៃប្រព័ន្ធច្បាប់ជាតិរបស់ប្រទេសដទៃបង្ហាញថា ដំណើរការនៃប្រព័ន្ធតុលាការ គឺជាបុរេលក្ខខណ្ឌសម្រាប់ការចាប់ផ្តើមរាប់ថិរវេលានៃអាជ្ញាយុកាល[២៥]។

---

[២៤] សូមមើលកថាខណ្ឌ ១៤។

[២៥] ឧទាហរណ៍ អង្គនីតិបញ្ញត្តិអាល្លឺម៉ង់សម្រេចថា តុលាការអាល្លឺម៉ង់មិនដំណើរការឡើយ ចាប់ពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៤៩។ ពោលគឺ រហូតដល់ការត្រួតត្រាកាន់កាប់ត្រូវបានបញ្ចប់ ហើយរដ្ឋធម្មនុញ្ញថ្មីបានចូលជាធរមាន (និងក្នុងអំឡុងការជំនុំជម្រះក្តីនៅ Nuremberg និងការជំនុំជម្រះក្តីក្រោយ Nuremberg នៅក្នុងតំបន់ដែលត្រូវបានត្រួតត្រា) (Gesetz ueber die Berechnung strafrechtlicher Verjährungsfrisften, BGB1 I 1965, 315 ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៦៥)។ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៨៦៤ សភាសហរដ្ឋអាមេរិក បានអនុម័ត "ច្បាប់មួយ ទាក់ទងទៅនឹងថិរវេលានៃអាជ្ញាយុកាលនៅក្នុងរឿងក្តីមួយចំនួន" ដែលចែងថា "នៅពេលណាក៏ដោយ ក្នុងអំឡុងពេលអត្ថិភាពនៃការបះបោរប្រឆាំងពេលនេះ បណ្តឹងណាក៏ដោយ មិនថាជាបណ្តឹងរដ្ឋប្បវេណី ឬបណ្តឹងព្រហ្មទណ្ឌឡើយ ត្រូវធ្វើឡើងប្រឆាំងលើបុគ្គលណាដែលដំណើរការសម្រាប់ការចាប់ផ្តើមបណ្តឹងនោះ ឬការចាប់ខ្លួនបុគ្គលនោះមិនអាចត្រូវបានអនុវត្តលើបុគ្គលនោះបាន ដោយសារតែការជំទាស់ប្រឆាំងទៅនឹងការអនុវត្តច្បាប់របស់សហរដ្ឋអាមេរិក ឬក៏ការបញ្ឈប់មិនដំណើរការតាមប្រក្រតីនៃដំណើរការនីតិវិធីតុលាការ ; ឬនៅពេលណាក៏ដោយ បន្ទាប់ពីបណ្តឹងបែបនេះ មិនថាជាបណ្តឹងរដ្ឋប្បវេណី ឬបណ្តឹងព្រហ្មទណ្ឌឡើយ ត្រូវបានធ្វើឡើងនោះ បុគ្គលនោះមិនអាចប្រឈមជាមួយដំណើរការសម្រាប់ការចាប់ផ្តើមបណ្តឹងបែបនោះឡើយ ដោយសារតែការជំទាស់ប្រឆាំងទៅនឹងច្បាប់ ឬក៏ការបញ្ឈប់មិនដំណើរការនៃដំណើរការនីតិវិធីតុលាការ ៖ រយៈពេល ដែលក្នុងអំឡុងពេលនោះបុគ្គលនោះត្រូវស្ថិតនៅហួសពីការអនុវត្តបាននៃដំណើរការនីតិវិធីតុលាការ មិនអាចត្រូវបានពិចារណា ឬចាត់ទុកថាជាផ្នែកនៃរយៈពេលដែលកំណត់ដោយច្បាប់ សម្រាប់ការចាប់ផ្តើមនៃបណ្តឹងបែបនោះឡើយ"។ (ដកស្រង់នៅក្នុងរឿងក្តី *Stewart ទល់នឹង Kahn*, 78 U.S. 11 Wall., 493 (1870) E9/8.5។ សូមមើលតុលាការកំពូលរបស់សហរដ្ឋអាមេរិក : រឿងក្តី *Hanger ទល់នឹង Abbott*, 73 U.S. 532, 1867 WL 11246 (U.S. Ark.) E9/7.14 (រកឃើញថា ថិរវេលានៃអាជ្ញាយុកាល (សម្រាប់

១៨. ឥឡូវនេះ ចៅក្រមកម្ពុជានឹងធ្វើការពិចារណាលើបញ្ហាអង្គហេតុនៅចំពោះមុខខ្លួន ដើម្បីឈានដល់ការសន្និដ្ឋានថា យ៉ាងហោចណាស់ក៏ថិរវេលានៃអាជ្ញាយុកាលដែលមានចែងនៅក្នុងក្រមឆ្នាំ១៩៥៦ មិនត្រូវបានរាប់ទេរហូតដល់ឆ្នាំ១៩៩៣ នោះ។

១៩. ជាបឋម ទោះបីជាមានការជំនុំជម្រះមួយចំនួនដោយតុលាការកម្ពុជា នៅក្នុងអំឡុងពេលនោះ (ចាប់តាំងពីឆ្នាំ១៩៨២) ក៏ដោយ ក៏ចៅក្រមកម្ពុជាយល់ឃើញថា សមត្ថភាពតុលាការកម្ពុជាមានការខ្វះខាតច្រើនណាស់នាពេលនោះ ដោយសារតែការបំផ្លិចបំផ្លាញប្រព័ន្ធតុលាការទាំងស្រុងដោយរបបកម្ពុជាប្រជាធិបតេយ្យ។ ផ្អែកតាមភស្តុតាង និងសម្ភារៈ ឯកសារដទៃទៀតនៅចំពោះមុខខ្លួន ចៅក្រមកម្ពុជាសន្និដ្ឋានថា វាត្រូវការពេលវេលាយូរអង្វែង ដើម្បីបង្កើតប្រព័ន្ធតុលាការឡើងវិញ ដើម្បីបណ្តុះបណ្តាលមេធាវី រដ្ឋអាជ្ញា(ព្រះរាជអាជ្ញា) និងចៅក្រម។ ជាឧទាហរណ៍ រយៈពេលនេះបានអូសបន្លាយរហូតមកដល់ឆ្នាំ១៩៨០ និងឆ្នាំ១៩៨២ ដើម្បីចេញ ក្រឹត្យ-ច្បាប់ ទាក់ទងនឹងការបង្កើតតុលាការ[២៦] ហើយរហូតដល់ឆ្នាំ ១៩៨៥ និងឆ្នាំ១៩៨៧ ទើបចេញ ក្រឹត្យ-ច្បាប់ ស្តីពីការបង្កើតតុលាការកំពូល[២៧]។ នៅក្នុងឆ្នាំ១៩៨០ ក្រឹត្យ-ច្បាប់ មួយត្រូវបានអនុម័តឡើងដោយ

---

បណ្តឹងរដ្ឋប្បវេណី) មិនបានចាប់ផ្តើមរាប់ឡើយ ក្នុងខណៈដែលតុលាការនៅក្នុងរដ្ឋ Arkansas បានបិទមិនដំណើរការដោយសារតែការបះបោរ ប្រឆាំងដែលមានរយៈពេលបីឆ្នាំ))។ ច្បាប់បារាំងចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៥០ ដែលច្បាប់នេះធ្វើវិសោធនកម្មនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៤២ ដែលចែងពាក់ព័ន្ធនឹង "អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា និងទោស" បានចែងថា ៖ «រាល់គ្រប់បទល្មើសមិនត្រូវបានកំណត់ក្នុងអាជ្ញាយុកាលនៃច្បាប់នេះ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា [...] ត្រូវបានព្យួររហូតដល់ថ្ងៃបញ្ចប់នៃអរិភាព"។ (រដ្ឋកិច្ចរបស់សាធារណរដ្ឋបារាំង ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៥០ ច្បាប់លេខ ៥០-៥២៩ ទំព័រ ៥២៤៣។ ច្បាប់នេះបានព្យួរ ថិរវេលានៃអាជ្ញាយុកាលនៅក្នុងអំឡុងពេលមានសង្គ្រាម។ នៅពេលបញ្ចប់អរិភាព ថិរវេលានៃអាជ្ញាយុកាលត្រូវបានរាប់ឡើងវិញ និងត្រូវបានបន្តរាប់ថិរវេលាដែលនៅសល់ពីពេលចាប់ផ្តើមអរិភាពទាំងនោះ។

[២៦] ច្បាប់-ក្រឹត្យ លេខ១ ស្តីអំពីការបង្កើតតុលាការប្រជាជនបដិវត្តន៍ (ខេត្តនានា និងរាជធានី) (ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨០)។ ឯកសារ E9/9.3, ERN (ភាសាអង់គ្លេស) 00336567-00336569។ ច្បាប់-ក្រឹត្យ លេខ១ ស្តីអំពីការបង្កើតតុលាការប្រជាជនបដិវត្តន៍ (ខេត្តនានា និងរាជធានី) (ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨២)។ ច្បាប់-ក្រឹត្យលេខ២៖ ច្បាប់ ស្តីពីការចាត់តាំងតុលាការ និងអយ្យការ (ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២)។

[២៧] ច្បាប់-ក្រឹត្យ លេខ២៨ ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨៥)។ ក្រឹត្យ-ច្បាប់ លេខ៣៤ ស្តីពីការចាត់តាំង និងសកម្មភាពរបស់តុលាការប្រជាជាតិកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល (ថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៨៧)។

មានអានុភាពប្រតិសកម្មទៅទល់ នឹងថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩[២៨]។ អាស្រ័យហេតុនេះ ចៅក្រមកម្ពុជាយល់ឃើញថា ចាប់តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨២ ប្រព័ន្ធតុលាការនៃរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជាមិនមានដំណើរការទាល់តែសោះ និងបានដំណើរការតែក្នុងទ្រង់ទ្រាយមួយមានកម្រិតបំផុតនៅក្នុងអំឡុងឆ្នាំក្រោយៗមក។ ប៉ុន្តែ ភាពទន់ខ្សោយនៃប្រព័ន្ធតុលាការតែមួយមុខនោះ មិនមែនជាមូលហេតុគ្រប់គ្រាន់ក្នុងការបង្ហាញថា ជនជាប់ចោទមិនអាចត្រូវបានស៊ើបអង្កេត ឬចោទប្រកាន់ក្រោយឆ្នាំ១៩៨២ ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក នោះទេ។

២០. ចៅក្រមកម្ពុជាក៏យល់ឃើញផងដែរថា រហូតមកទល់នឹងពេលដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ បញ្ហាប្រវត្តិសាស្ត្រ និងបរិការណ៍បានរាំងយ៉ាងខ្លាំងដល់លទ្ធភាពក្នុងការចោទប្រកាន់ និងការស៊ើបសួរ ជាពិសេសចំពោះឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់លើជនជាប់ចោទ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក លើរូបបុគ្គលនោះ ៖

ក) ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៨ ព្រះរាជាណាចក្រកម្ពុជាបានទទួលរងសង្គ្រាមស៊ីវិល ដែលនៅក្នុងអំឡុងពេលនោះ ពួកខ្មែរក្រហមបានគ្រប់គ្រងផ្នែកខ្លះនៃទឹកដីរបស់ប្រទេសកម្ពុជា[២៩]។

ខ) ខ្មែរក្រហម និងសម្ព័ន្ធមិត្តរបស់ពួកគេ ក៏ត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជារដ្ឋាភិបាលរបស់ប្រទេសកម្ពុជាផងដែរ[៣០]។

---

[២៨] ក្រឹត្យ-ច្បាប់ លេខ២ ស្តីពីការផ្តន្ទាទោសក្បត់បដិវត្តន៍ និងបណ្តាទោសប្រព្រឹត្តបទល្មើសផ្សេងៗទៀត (ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០) E9/9.4។

[២៩] កិច្ចព្រមព្រៀងស្តីពីការដោះស្រាយបញ្ហាជម្លោះនយោបាយនៅក្នុងប្រទេសកម្ពុជា (ជាមួយនឹងឧបសម្ព័ន្ធ) *សម្រេចនៅទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១* (អត្ថបទធ្វើជាភាសាអង់គ្លេស ចិន បារាំង ខ្មែរ និងរុស្ស៊ី) 1663 UNTS No. 28613 ("កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១")។ សូមមើលសៀវភៅរបស់ Craig Etcheson « បន្ទាប់ពីវាលពិឃាដ »៖ "មេរៀននៃការប្រល័យពូជសាសន៍ទៅលើប្រជាជនកម្ពុជា" 13 (2005).4.14 ERN 00078730-000 78731ទំព័រ៩-១០ (យោងតាមសេចក្តីសន្និដ្ឋានរបស់ ការិយាល័យសហព្រះរាជអាជ្ញា)។ សៀវភៅរបស់ Nayan Chanda "សត្រូវបងប្អូនឯង"៖"សង្គ្រាម បន្ទាប់ពីសង្គ្រាម" នៅក្នុងឯកសារ E3/193, ERN00192562 ទំព័រ ៣៧៧។

គ) រហូតមកដល់ឆ្នាំ១៩៩៣ ដូចបានលើកឡើងខាងលើ ប្រព័ន្ធតុលាការជាតិដែលខ្សោយនោះ គឺជាប្រព័ន្ធតុលាការរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា (រហូតដល់ឆ្នាំ១៩៨៩) និងក្រោយមកក្លាយជារដ្ឋកម្ពុជា (ឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៣)។ ការខិតខំប្រឹងប្រែងដើម្បីទទួលបានសន្តិភាព គឺជាបញ្ហាសំខាន់បំផុតនៅពេលនោះដែលបានចាប់ផ្តើមពីឆ្នាំ១៩៨៥ [៣១] ។ ខ្មែរក្រហមគឺជាភាគីមួយដ៏សំខាន់បំផុតក្នុងចូលរួមចរចាសន្តិភាពនាពេលនោះ។ ដោយសារតែប្រព័ន្ធយុត្តិធម៌មិនទាន់មានឯករាជភាពពេញលេញផងនោះ [៣២] ការពិចារណាខាងទិដ្ឋភាពនយោ-

---

[៣០] ខ្មែរក្រហមបានតំណាង ប្រទេសកម្ពុជា នៅក្នុងអង្គការសហប្រជាជាតិ ពីចន្លោះពី ឆ្នាំ ១៩៧៩ ដល់ ១៩៨២ ក្នុងឈ្មោះជា "កម្ពុជាប្រជាធិបតេយ្យ" ។ ចាប់ពីឆ្នាំ ១៩៨៣ ដល់ ឆ្នាំ ១៩៩០ ពួកគេបានតំណាងប្រទេសកម្ពុជានៅក្នុងអង្គការសហប្រជាជាតិ ។ ពួកគេបានតំណាងប្រទេសកម្ពុជានៅក្នុងអង្គការសហប្រជាជាតិមួយក្រុមផ្សេងទៀតរបស់កម្ពុជាដែលមានឈ្មោះថា "រាជរដ្ឋាភិបាលចំរុះនៃកម្ពុជាប្រជាធិបតេយ្យ។ នៅឆ្នាំ១៩៩០ រាជរដ្ឋាភិបាលចំរុះនេះ បានប្តូរឈ្មោះមកជា" "រាជរដ្ឋាភិបាលជាតិកម្ពុជា"។ សូមមើលសៀវភៅរបស់ NayanChanda «សត្រូវបងប្អូនឯង»៖ "សង្គ្រាម បន្ទាប់ពី សង្គ្រាម" ឯកសារ E3/193 ERN00192562 ទំព័រទី៣៧៧។ សូមមើល សៀវភៅរបស់ Raoul M. Jennar "កូនសោប្រទេសកម្ពុជា" ឯកសារ E3/515, ERN (Fr) 00385773, 00385826- 00385847 ទំព័រ 29, 84-105 (ពិពណ៌នាអំពី អាសនៈនៅអង្គការសហប្រជាតិថា "នៅសល់ទំនេរតាមព្រឹត្តិន័យ" ក្នុងឆ្នាំ១៩៩០។

[៣១] សូមមើល សៀវភៅរបស់ Raoul M. Jennar "កូនសោប្រទេសកម្ពុជា" ឯកសារ E3/515, ERN (Fr) 00385773,00385838,00385841 ទំព័រទី ២៩, ៩៦ និង ៩៩។ សូមមើលសេចក្តី សំរេច លេខ៦៦៨ របស់ ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ១៩៩០។ សូមមើលផងដែរ សេចក្តីសំរេច របស់មហាសន្និបាតរបស់អង្គការសហប្រជាជាតិ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩០។

[៣២] *សូមមើល* មាត្រា៦០ នៃរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាឆ្នាំ១៩៨១។ ក្រិតច្បាប់លេខ៤ ស្តីពីការបង្កើតរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា (ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២)។ សៀវភៅ *ប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជា* របស់លោក Koy Neam ( ទំព័រទី៤ E9/9.10, ERN 00336591)។ សៀវភៅ *គេសំលាប់អ្នកច្បាប់ទាំងអស់* របស់លោក K. Neilson (E9/5.26, ERN00333020-00333022 ទំព័រ 2-4)។ កថាខណ្ឌទី២១២ នៃរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាផ្តល់ឲ្យគណៈកម្មាធិការសិទ្ធិមនុស្សក្នុងឆ្នាំ១៩៩៣ (ICCPR/C/81/ADD. 12, 23 September 1998), E9/6.8, ERN (FR) 00333208។ កថាខណ្ឌទី៤៣នៃរបាយការណ៍របស់អង្គការសហប្រជាជាតិស្តីពី ការបង្កើតក្រុមអ្នកជំនាញសម្រាប់កម្ពុជា អនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាទអង្គការសហប្រជាជាតិ លេខ52/135, A/53/850-S/1999/231 ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ (E9/5.13, ERN 00330672)។ របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស (លោក Michael Kirby ជនជាតិអូស្ត្រាលី) ផ្តល់ឲ្យគណៈកម្មការស្តីពីសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ១៩៩៤ (E/CN.4/1994/73,

បាយបែបនេះឃើញថា ការស៊ើបអង្កេត និងការចោទប្រកាន់ចំពោះ ឧក្រិដ្ឋកម្មនានានាដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែលជនជាប់ចោទ បានប្រព្រឹត្ត គឺមិនអាចផ្តើមធ្វើទៅបានឡើយ។

ឃ) ចៅក្រមកម្ពុជាបានកត់សម្គាល់បន្ថែមថា ចាប់តាំងពីឆ្នាំ១៩៧៩ ជនជាប់ចោទបានបន្តបម្រើឱ្យរបបកម្ពុជាប្រជាធិបតេយ្យ រួមបញ្ចូលទាំងពេលដែលគាត់ធ្វើជាគ្រូបង្រៀននៅក្នុងប្រទេសចិនផង រហូតដល់ពេលគាត់បានដាច់ទំនាក់ទំនងជាមួយមេរបស់គាត់ នៅក្នុងអំឡុងឆ្នាំ១៩៩៣។ យោងតាមចម្លើយរបស់ជនជាប់ចោទដែលបានដាក់ជូនសហចៅក្រមស៊ើបអង្កេត[៣៣] គាត់បានដកខ្លួនចេញពីខ្មែរក្រហមហើយ នៅពេលនោះ។ ជនជាប់ចោទបានប្រើឈ្មោះផ្សេង (ហាង់ ពិន) នៅពេលគាត់ធ្វើជាគ្រូបង្រៀនឱ្យព្រះរាជាណាចក្រកម្ពុជា បន្ទាប់មកគាត់បានត្រឡប់ទៅនៅលើទឹកដីដែលត្រួតត្រាដោយពួកខ្មែរក្រហម និងជាទីកន្លែងដែលគាត់ត្រូវបានចាប់ខ្លួនដោយអាជ្ញាធរកម្ពុជាក្នុងឆ្នាំ១៩៩៩ ក្រោយពេលដែលខ្មែរ ក្រហមត្រូវបានរំលាយជាចុងក្រោយនោះ[៣៤]។ ខណៈដែលគាត់ស្ថិតនៅក្រោមការការពាររបស់ខ្មែរក្រហម ដូច្នេះហើយទើបជនជាប់ចោទមាននិទ្ទណ្ឌភាពរួចផុតពីការស៊ើបអង្កេត ឬការចោទប្រកាន់ទាំងអស់[៣៥]។

---

E9/6.6, ERN (Fr) 00333197, 00333198 កថាខណ្ឌទី១៣៧ (E9/6.6), ERN (Fr) 00333197, 00333198 កថាខណ្ឌ១៣៧ និង ១៥៥។

[៣៣] កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ E3/11 ERN (ភាសាខ្មែរ) 00158839-00158840 ទំព័រ៥-៦។

[៣៤] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៦៦។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៧២-៧៥ និងប្រតិចារឹក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (ជនជាប់ចោទ) ទំព័រ៣៤-៣៨ (រៀបរាប់អំពីការនៅមានភក្តីភាពរបស់គាត់ចំពោះខ្មែរក្រហម រហូតដល់ពេលចាប់ខ្លួនគាត់ (ទោះបីជាការស្រលាញ់របស់គាត់មានការធ្លាក់ចុះក្តី))។

[៣៥] ចៅក្រមកម្ពុជាបានសម្គាល់ឃើញថា យោងតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ វាមិនមែនជាមូលហេតុនៃការព្យួរ ឬផ្តាច់ចិរវេលានៃអាជ្ញាយុកាលទេនៅពេលជនសង្ស័យរត់គេចខ្លួនពីយុត្តាធិការរបស់រដ្ឋនោះ ព្រោះរដ្ឋអាចចាប់ផ្តើមធ្វើការស៊ើបអង្កេតបាន។ នៅក្រោមយុត្តាធិការរបស់រដ្ឋខ្លះ ការរត់គេចខ្លួនពីយុត្តាធិការរបស់រដ្ឋ គឺជាមធ្យោបាយសំរាប់ពន្យារអាជ្ញាយុកាល (ឧទាហរណ៍ ផ្នែកទី៣២៩០ នៃជំពូកទី១៨ នៃក្រមរបស់សហរដ្ឋអាមេរិក)។ ជនជាប់ចោទមិនគ្រាន់តែរត់គេចខ្លួនពីយុត្តាធិការរបស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបន្តបម្រើឱ្យខ្មែរក្រហមថែមទៀតផង។

២១. កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដែលបានធ្វើឡើងនៅក្នុងឆ្នាំ១៩៩១ សង្កត់ធ្ងន់ទៅលើឥទ្ធិពលអស្ថេរភាពនៃជម្លោះដែលមានតាំងពីមុនកិច្ចព្រមព្រៀងមកម្ល៉េះ៖

> សន្និសីទទីក្រុងប៉ារីសស្តីពីកម្ពុជា ត្រូវបានកោះប្រជុំតាមការអញ្ជើញរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ក្នុងទិសដៅឈានទៅដល់ដំណោះស្រាយរួមមួយ ដោយមានការធានាជាអន្តរជាតិ ដែលនឹងនាំសន្តិភាពមកឲ្យប្រទេសវិញ ដែលបានឆ្លងកាត់ជម្លោះប្រកបដោយសោកនាដកម្ម និងការបង្ហូរឈាមនេះ [...][៣៦]។

២២. កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បាននិយាយបន្ថែមទៀតអំពីស្ថានភាពអស្ថេរភាពនៅក្នុងប្រទេសកម្ពុជា ដោយចង្អុលបង្ហាញពីវិធានការកម្រិតខ្ពស់ ដែលបានប្រើប្រាស់ដើម្បី "[...] បញ្ចប់ការបង្ហូរឈាមនៅកម្ពុជាក្នុងពេលដ៏ឆាប់បំផុត តាមដែលអាចធ្វើទៅបាន"[៣៧]។ កិច្ចព្រមព្រៀងនេះ ក៏បាននិយាយយោងទៅលើតម្រូវការឲ្យដោះលែងអ្នកទោសសង្គ្រាម និងអ្នកទោសជាជនស៊ីវិលដើម្បី "ស្តារនិងរក្សាសន្តិភាពនៅកម្ពុជា លើកស្ទួយការផ្សះផ្សាជាតិ ... [និងដាក់ចេញ] នូវវិធានការពិសេសដើម្បីធានាដល់ការការពារ...សិទ្ធិមនុស្ស និងការធានាមិនឲ្យគោលនយោបាយ និងអំពើប្រព្រឹត្តនៅក្នុងអតីតកាលវិលត្រឡប់មកវិញជាដាច់ខាត"[៣៨]។ សេចក្តីថ្លែងទាំងអស់នេះ បញ្ជាក់អះអាងថា រហូតមកដល់រយៈពេលខ្លីបំផុត មុនការកោះប្រជុំសន្និសីទទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១ ស្តីពីសន្តិភាពនៅកម្ពុជា ប្រទេសកម្ពុជាស្ថិតក្នុងភ្នក់ភ្លើងសង្គ្រាម ដែលបានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធភាពនៃប្រព័ន្ធច្បាប់របស់ប្រទេស ដើម្បីធានាការពារដល់សិទ្ធិជាមូលដ្ឋាន។

---

[៣៦] កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ កថាខណ្ឌ១។

[៣៧] កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ កថាខណ្ឌ៨។

[៣៨] បុព្វកថា កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១។ *សូមមើលបន្ថែម* បុព្វកថានៃច្បាប់អ៊ុនតាក់ឆ្នាំ១៩៩២ ដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានកត់សម្គាល់យ៉ាងច្បាស់ថា "ដោយមានកង្វល់ថា បណ្តារចនាសម្ព័ន្ធ ច្បាប់ និងស្ថាប័នតុលាការនៅប្រទេសកម្ពុជា មិនបំពេញឲ្យបានពេញលេញតាមការតម្រូវរបស់កិច្ចព្រមព្រៀងប៉ារីស ព្រមទាំងពេលខ្លះមានការខ្វះខាតមួយផ្នែក ឬពុំទាន់មានអ្វីទាល់តែសោះ ហើយបើតាមការពិនិត្យពិច័យ គឺមិនសមស្របដើម្បីធានាឲ្យមានរបៀបរៀបរយ និងសិទ្ធិមនុស្សនៅតាមទីកន្លែងនានាជាច្រើនក្នុងដែនដី" និង "ដោយទទួលស្គាល់ថា បញ្ហាទាំងនេះត្រូវនៅក្រោមការទទួលខុសត្រូវរបស់អ៊ុនតាក់ ដើម្បីសម្រួលការរៀបចំរចនាសម្ព័ន្ធទាំងឡាយ ច្បាប់ និងស្ថាប័នតុលាការ នៅកន្លែងណាដែលខ្វះខាតហើយជួយកែលម្អ កន្លែងណាដែលមានរួចហើយ ដើម្បីឲ្យសមស្របតាមការតម្រូវចាំបាច់នៃកិច្ចព្រមព្រៀង"។

២៣. កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសបានបើកឱ្យមានអំឡុងពេលអន្តរកាលមួយ ដែលអាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា បានបន្តគោលបំណងបេសកកម្មរបស់ខ្លួន ទៅលើការត្រួតពិនិត្យដំណើរការរំសាយអាវុធ និងការបោះឆ្នោតដោយប្រជាធិបតេយ្យ ដែលបានរៀបចំឡើងក្នុងឆ្នាំ១៩៩៣ [៣៩] ។ ប៉ុន្តែ នៅក្នុងអំឡុងពេលអន្តរកាលនេះ ខ្មែរក្រហមគឺជាសមាជិកនៃឧត្តមក្រុមប្រឹក្សាជាតិនៃកម្ពុជា ដែលជាស្ថាប័នស្របច្បាប់តែមួយគត់ និងជាប្រភពនៃជាអាជ្ញាធរនៅកម្ពុជា។

២៤. កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បាននាំទៅដល់ការបង្កើតរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ការបង្កើតនូវគោលការណ៍នៃប្រព័ន្ធតុលាការមួយឯករាជ្យ និងបាននាំឱ្យមានការគាំទ្រជាអន្តរជាតិថ្មីមួយមកលើរាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៣ តាមរយៈការបោះឆ្នោតដោយមិនមានការចូលរួមពីពួកខ្មែរក្រហម [៤០] ។ ប្រាកដណាស់ថា ការរៀបចំឱ្យមានតុលាការ គឺជាកម្មវត្ថុរបស់អង្គនីតិប្បញ្ញត្តិនាឆ្នាំនោះ [៤១] ប៉ុន្តែស្ថានភាពជាក់ស្ដែង ដែលតុលាការនេះដំណើរការមិនអាចផ្លាស់ប្តូរភ្លាមៗបានទេ។ ទោះជាយ៉ាងណាក៏ដោយ ចាប់តាំងពីពេលនោះមក រាជរដ្ឋាភិបាលថ្មីមានលទ្ធភាពអនុម័តច្បាប់ថ្មីៗជាច្រើន រួមទាំងច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ក្នុងឆ្នាំ១៩៩៤ ហើយនៅក្នុងឆ្នាំ១៩៩៧ បានស្នើសុំឱ្យមានជំនួយពីអង្គការសហប្រជាជាតិដើម្បីចរចា និងផ្តន្ទាទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទៀតផង [៤២]។

---

[៣៩] កិច្ចព្រមព្រៀងទីក្រុងប៉ារីស ឧបសម្ព័ន្ធ I។

[៤០] មាត្រា១០៩ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[៤១] ក្រឹត្យ-ច្បាប់ លេខ០៦ដ របស់ក្រុមប្រឹក្សារដ្ឋ និងសភាជាតិ (ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា)។

[៤២] *សូមមើល* លិខិតចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ ពីរាជរដ្ឋាភិបាលកម្ពុជា ស្នើសុំជំនួយរបស់អង្គការសហប្រជាជាតិដើម្បីស៊ើបសួរ និងចោទប្រកាន់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ (ឯកសារអង្គការសហប្រជាជាតិ A/51/930-S/1997/488 (ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៧)។ ឯកសារអង្គការសហប្រជាជាតិ A/RES/52/135 (ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៨ កថាខណ្ឌ១៦)។ ច្បាប់ស្តីពីការដាក់ "ក្រុមកម្ពុជាប្រជាធិបតេយ្យ" ឱ្យនៅក្រៅច្បាប់ ប្រកាសឱ្យប្រើនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ (ច្បាប់លេខ 01.NS.94)។ សូមមើលផងដែរ បុព្វកថានៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការចោទប្រកាន់នៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

២៥. តាមហេតុការណ៍នានាដូចបានលើកឡើង ចៅក្រមកម្ពុជា យល់ស្របជាមួយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីថា [៤៣] ចិរវេលានៃអាជ្ញាយុកាលពាក់ព័ន្ធទៅនឹងបទល្មើសជាតិ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ចាប់ផ្តើមរាប់ ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ នៅពេលដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើង ហើយចិរវេលានៃអាជ្ញាយុកាលនៅមុនកាលបរិច្ឆេទនេះ មិនអាចរាប់បានទេ។ ចៅក្រមកម្ពុជាមិនចាំបាច់សម្រេចថាតើចិរវេលានៃអាជ្ញាយុកាលនេះត្រូវបានផ្តាច់ ឬក្បួរនោះទេ ដោយហេតុថា អានុភាពគតិយុត្តិនៃជម្រើសទាំងពីរនេះនាំឲ្យមានលទ្ធផលដូចគ្នា៖ ចិរវេលានៃអាជ្ញាយុកាល បានចាប់ផ្តើមរាប់ពីឆ្នាំ១៩៩៣។ ជនជាប់ចោទត្រូវបានចាប់ខ្លួនដោយអាជ្ញាធរកម្ពុជានៅក្នុងឆ្នាំ១៩៩៩ ពីការពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរស២១ [៤៤] ។ ផ្អែកតាមច្បាប់កម្ពុជា ការចាប់ខ្លួននាំឲ្យផ្តាច់ចិរវេលានៃអាជ្ញាយុកាល។ នេះមានន័យថាចិរវេលានៃអាជ្ញាយុកាលរយៈពេល ១០ ឆ្នាំ នឹងត្រូវចាប់ផ្តើមរាប់សារជាថ្មី នៅពេលបញ្ចប់រយៈពេលនៃការផ្តាច់នេះ[៤៥] ។ ការចាប់ផ្តើមកិច្ចស៊ើបអង្កេតរបស់ អ.វ.ត.ក លើជនជាប់ចោទគឺនៅក្នុងឆ្នាំ២០០៦។ ចៅក្រមកម្ពុជាយល់ឃើញថា ចិរវេលានៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មតាមច្បាប់ជាតិ មិនទាន់ផុតរលត់ទេ នៅក្នុងឆ្នាំ២០០៦ នោះ។

២៦. ចៅក្រមកម្ពុជាកត់សម្គាល់ថា សេចក្តីសម្រេចនេះទាក់ទងចំពោះតែអង្គហេតុ និងជនជាប់ចោទក្នុងរឿងក្តីនេះតែប៉ុណ្ណោះ។ ចៅក្រមមិនមែនជាអ្នកបង្កើតច្បាប់ទេ។ ចៅក្រមគ្រាន់តែជាអ្នកអាចវិនិច្ឆ័យសេចក្តីទៅលើស្ថានភាពនៃបុគ្គលម្នាក់ៗនៅក្នុងរឿងក្តីដែលមានចំពោះមុខខ្លួនតាមនីតិវិធីតែប៉ុណ្ណោះ។

---

[៤៣] *សូមមើល* សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៣០, ៣៦។ សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ កថាខណ្ឌទី១២។ សារណារបស់សហមេធាវីតំណាងឲ្យដើមបណ្តឹង រដ្ឋប្បវេណីក្រុម២ កថាខណ្ឌទី១២-១៣។ សារណារបស់សហមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ កថាខណ្ឌ៨-១៧។

[៤៤] *សូមមើល* "សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ" របស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា E39/5 ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩។

[៤៥] សូមមើលមាត្រា១១២ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ មាត្រា១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

២. <u>មតិយោបល់របស់យើងជាចៅក្រមអន្តរជាតិ ចៅក្រម Cartwright ចៅក្រម Lavergne</u>

២៧. ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយចៅក្រមកម្ពុជាថា ច្បាប់ជាតិជាច្រើនបានកំណត់ពីកត្តាមួយចំនួនដែលបានព្យួរ ឬផ្តាច់ការរាប់ថិរវេលានៃអាជ្ញាយុ-កាល បន្ទាប់ពីផលវិបាកនៃអស្ថេរភាពជាតិ។ ទោះបីជារបបកម្ពុជាប្រជាធិបតេយ្យបានធ្វើឱ្យសមត្ថភាពតុលាការកម្ពុជាចុះខ្សោយ ដោយមិនអាចប្រកែកបាននៅក្នុងអំឡុងពេលនោះក៏ដោយ ក៏ចៅក្រមអន្តរជាតិសន្និដ្ឋានបានថា ថិរវេលានៃអាជ្ញាយុកាលដែលអាចអនុវត្តមិនត្រូវបានព្យួរនៅចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣នោះទេ។ អាស្រ័យហេតុនេះ ការចោទប្រកាន់ពីបទល្មើសជាតិមិនត្រូវបានផុតរលត់ឡើយនៅមុនពេលដែលមាត្រា៣ និងមាត្រា៣ថ្មី នៃច្បាប់ អ.វ.ត.ក ត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០១ និងឆ្នាំ២០០៤ នោះ។

*(i) លក្ខណៈវិនិច្ឆ័យសម្រាប់ការព្យួរ ឬការផ្តាច់ថិរវេលានៃអាជ្ញាយុកាល*

២៨. មិនមានវិធានជាធរមានទូទៅណាមួយនៅក្នុងកម្រិតអន្តរជាតិ បានបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ព្យួរ ឬផ្តាច់ថិរវេលានៃអាជ្ញាយុកាលនោះឡើយ។ អនុសញ្ញាស្តីពីភាពមិនអាចអនុវត្តបាននូវថិរវេលានៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលជាសន្ធិសញ្ញាពហុភាគី ដែលត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ១៩៦៨ បានចែងថា ដោយសារតែភាពធ្ងន់ធ្ងរ និងសារៈសំខាន់សម្រាប់បញ្ចប់និទ្ទណ្ឌភាពចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិ ឧក្រិដ្ឋកម្មបែបនេះមិនមានថិរវេលានៃអាជ្ញាយុកាលនោះទេ[៤៦]។ ទោះបីជាសន្ធិសញ្ញានេះអាចចាត់ទុកថាជានិយាមនៃការអនុវត្តទូទៅក្តី[៤៧] ក៏សន្ធិសញ្ញានេះមិនបានចែងច្បាស់អំពីការអនុវត្តបែបនេះ ចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិ ឬមិនបានលើកឡើងអំពីផលវិបាកនៃអស្ថេរភាពជាតិ ទៅលើថិរវេលានៃអាជ្ញាយុកាលដែលមានពីមុន ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងនោះឡើយ។

---

[៤៦] អនុសញ្ញាស្តីពីការមិនគិតនូវថិរវេលានៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លេខ 754 UNTS 73 *ចូលជាធរមាន* ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧០។

[៤៧] មកទល់ពេលនេះ សន្ធិសញ្ញានេះត្រូវបានផ្តល់សច្ចាប័នដោយប្រទេសចំនួន៥៣ ប្រទេស តែប៉ុណ្ណោះ។ ព្រះរាជាណាចក្រកម្ពុជាមិនមែនជាប្រទេសហត្ថលេខីទេ។

00573312



២៩. ការអនុវត្តរបស់រដ្ឋមួយចំនួន បានបញ្ជាក់ថា ចិរវេលានៃអាជ្ញាយុកាលអាចនឹងមិនរាប់នៅក្នុងអំឡុងពេលដែលប្រព័ន្ធតុលាការមិនមានសមត្ថភាព ដោយសារតែសង្គ្រាម ឬនៅពេលបទឧក្រិដ្ឋដែលចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើងដោយមន្ត្រីរបស់រដ្ឋនោះខ្លួនឯង។ ប៉ុន្តែការអនុវត្តភាគច្រើនរបស់រដ្ឋទាំងនោះ កើតចេញមកពីច្បាប់ជាតិដែលរៀបចំឡើងដើម្បីអាចធ្វើការចោទប្រកាន់ចំពោះបទល្មើសនានា ដែលចិរវេលានៃអាជ្ញាយុកាលនឹងត្រូវផុតរលត់[៤៨] ។ ផ្អែកតាមមូលហេតុដូចរៀបរាប់ខាងក្រោម ចៅក្រមអន្តរជាតិយល់ឃើញថា រហូតមកទល់ពេលបច្ចុប្បន្ននេះ មិនមានវិធានការណ៍ប្រហាក់ប្រហែលណាមួយត្រូវបានអនុមត័ដោយអង្គនីតិប្បញ្ញត្តិកម្ពុជាទេ[៤៩] ។ បន្ថែមពីលើនេះ មិនមានយុត្តិសាស្ត្រកម្ពុជា

---

[៤៨] សូមមើលឧទាហរណ៍ ច្បាប់បារាំងចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៥០ ដែលច្បាប់នេះធ្វើវិសោធនកម្មនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៤២ ដែលចែងពាក់ព័ន្ធនឹង ច្បាប់បារាំងចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៥០ ដែលច្បាប់នេះធ្វើវិសោធនកម្មនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៤២ ដែលចែងពាក់ព័ន្ធនឹង "អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា និងទោស" បានចែងថា ៖ "រាល់គ្រប់បទល្មើសដែលមិនត្រូវបានកំណត់ក្នុងអាជ្ញាយុកាល នៅពេលបោះពុម្ពផ្សាយច្បាប់នេះ អាជ្ញាយុកាលនៃ បណ្តឹងអាជ្ញា [...] ត្រូវបានព្យួររហូតដល់ថ្ងៃបញ្ចប់នៃអរិភាព" (រដ្ឋកិច្ចរបស់សាធារណរដ្ឋបារាំង ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៥០ ច្បាប់លេខ ៥០-៥២៩ ទំព័រ ៥២៤៣ ។ ច្បាប់នេះបានព្យួរ ចិរវេលានៃអាជ្ញាយុកាលនៅក្នុងអំឡុងពេលមានសង្គ្រាម។ នៅពេលបញ្ចប់នៃអរិភាព ចិរវេលានៃអាជ្ញាយុកាលត្រូវបានរាប់ឡើងវិញ និងត្រូវបានបន្តរាប់ចិរវេលាដែលនៅសល់តាំងពីពេលចាប់ផ្តើមអរិភាពទាំងនោះ។ នៅក្នុងរឿងក្តីផ្សេងទៀត ចិរវេលានៃអាជ្ញាយុកាល ត្រូវបានចាត់ទុកថាមិន រាប់ដោយសារមូលហេតុដែលមិនមានចែងឲ្យបានច្បាស់ក្នុងច្បាប់ជាតិ ប៉ុន្តែមូលហេតុទាំងនេះបែរជាត្រូវបានកំណត់ដោយយុត្តិសាស្ត្រ និងផ្អែកលើអសមត្ថភាពនៃប្រព័ន្ធច្បាប់ជាតិ ដើម្បីវិនិច្ឆ័យទោសចារីដែលប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរ ដែលចារីទាំងនោះទទួលខុសត្រូវដោយខ្លួនឯងផ្ទាល់ចំពោះការបន្តរបបជិះជាន់ និងការទប់ស្កាត់មិនឲ្យមានការស៊ើបសួរតាមផ្លូវតុលាការពិតប្រាកដណាមួយ ឬទម្រង់នៃសំណងដល់ជនរងគ្រោះ។ *សូមមើល ឧទាហរណ៍ រឿងក្តី Forti តទល់នឹង Suarez-Mason*, 672 F. Supp. 1531, 1550 (N.D. Cal. 1998) (កត់សម្គាល់ថា ទោះបីជាចិរវេលានៃ អាជ្ញាយុកាលដែលអាចអនុវត្តបានផុតរលត់យូរមកហើយ ប៉ុន្តែជនរងគ្រោះនៃរបបផ្តាច់ការយោធាអាហ្សង់ទីនមិន អាចស្វែងរកការប្តឹងតាមផ្លូវតុលាការបានទេ តម្រូវឲ្យមានការព្យួរ ឬផ្អាច់ដោយសមធម៌ (ការព្យួរ ឬការផ្អាច់) នៃចិរវេលានៃអាជ្ញាយុកាល ដោយសារតែការរាលដាលនៃការគ្រប់គ្រងរបស់របបយោធាដ៏គួរឲ្យភ័យខ្លាចអាចសម្រេចឲ្យដើមបណ្តឹងបង្ហាញថា សមាជិករបស់តុលាការ បានធ្វេសប្រហែសមិនបានអនុវត្តច្បាប់ដែលដោះស្រាយភាពភ័យ ខ្លាច នៃការក្លាយជាជនរងគ្រោះបន្ទាប់នៃ "សង្គ្រាមដ៏អាក្រក់នោះ")។

[៤៩] *សូមមើល យោងខាងក្រោម* កថាខណ្ឌ៤៦-៤៩ (កត់សម្គាល់ថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ២០០១ ដែលវិភាគមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក ប៉ុន្តែសេចក្តីសម្រេចនេះមិនបានព្យួរចិរវេលានៃអាជ្ញាយុកាលដែលអាចអនុវត្តគឺមិនដូចគ្នានឹងវិធានការទាំងនោះទេ)។

ដែលបង្ហាញអំពីថិរវេលានៃអាជ្ញាយុកាល ដែលត្រូវបានព្យួរ ឬផ្អាក់ ដោយសារតែអសមត្ថភាពនៃប្រព័ន្ធតុលាការនៅមុនឆ្នាំ១៩៩៣ ដាក់ជូនអង្គជំនុំជម្រះទេ។

៣០. ទោះបីជាច្បាប់ជាតិដែលពាក់ព័ន្ធមិនបានចែងច្បាស់ អំពីអសមត្ថភាពរបស់ប្រព័ន្ធតុលាការកម្ពុជា និងការជាប់ទាក់ទងដែលអាចមានចំពោះថិរវេលានៃអាជ្ញាយុកាលដែលអាចអនុវត្តក៏ដោយ ក៏ថៅក្រមអន្តរជាតិយល់ឃើញថា មានការណែនាំតិចតួចណាស់ ដែលគេអាចស្វែងរកបានពីលិខិតុបករណ៍អន្តរជាតិ និងការអនុវត្តថ្នាក់ជាតិ ដូចបានលើកឡើងខាងលើ[៥០]។ ថៅក្រមអន្តរជាតិពិចារណាថា តើផលប៉ះពាល់អាក្រក់ពីសម័យខ្មែរក្រហម អាចធ្វើឱ្យថៅក្រមអន្តរជាតិយល់ឃើញថា ថិរវេលានេះត្រូវបានផ្អាក់ ឬព្យួរ នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដែរឬយ៉ាងណា។

*(ii) ភស្តុតាងពាក់ព័ន្ធជាមួយនឹងដំណើរការនៃប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជា មុនខែកញ្ញា ឆ្នាំ១៩៩៣*

៣១. គោលការណ៍នានាដែលកើតចេញពីការអនុវត្តថ្នាក់ជាតិ ពាក់ព័ន្ធនឹងការផ្អាក់ ឬការព្យួរថិរវេលានៃអាជ្ញាយុកាល តម្រូវឱ្យបង្ហាញភស្តុតាងអំពីអសមត្ថភាពជាក់ច្បាស់នៃប្រព័ន្ធច្បាប់កម្ពុជាចំពោះកម្រិតបទដ្ឋានដែលចាំបាច់ ក្នុងការបំពេញកិច្ចស៊ើបសួរ ឬការចោទប្រកាន់ ដោយសារតែផលវិបាកនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គ្មានការជំទាស់ចំពោះការលើកឡើងថា ប្រព័ន្ធតុលាការក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យអសមត្ថភាព និងមិនមានលទ្ធភាពក្នុងការស៊ើបសួរ ឬការចោទប្រកាន់ចំពោះបទឧក្រិដ្ឋនានា នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ[៥១]។ ប៉ុន្តែ អយ្យការខកខានមិនបានបំពេញភារកិច្ចស្វែងរកបន្ទុកនៃភស្តុតាងដើម្បីបង្ហាញថា ផ្អែកតាមអង្គហេតុជាក់ស្តែង ពុំមានការចោទប្រកាន់ ឬការស៊ើបសួរលើបទឧក្រិដ្ឋទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅក្នុងរបបនេះ អាចនឹងត្រូវបានធ្វើឡើងនៅចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ នោះទេ បើទោះបីជាប្រព័ន្ធតុលាការនោះមានបញ្ហាធនធាន បញ្ហាសន្តិសុខ និងឧបសគ្គផ្សេងៗទៀតក៏ដោយ។

---

[៥០] *ប្រៀបធៀប* មាត្រា៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក (ចែងថា ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ "គេអាចស្វែងរកការណែនាំ ក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ")។

[៥១] សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជសដ *កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ផ្នែក ២.២.៣។ សូមមើល ដូចយោងខាងលើ កថាខណ្ឌ១៤។

៣២. សម្ភារៈឯកសារដែលមាននៅក្នុងសំណុំរឿង ទាក់ទងនឹងផលវិបាកនៃរបបកម្ពុជាប្រជាធិបតេយ្យ បានបង្ហាញអំពីប្រព័ន្ធតុលាការទន់ខ្សោយខ្លាំង និងដំណើរការដោយមិនមានលក្ខណៈពេញលេញ ដោយសារតែប្រព័ន្ធនេះរងផលប៉ះពាល់ពីការបំផ្លាញស្ថាប័នសាធារណៈ និងបុគ្គលិកដែលមានសមត្ថភាពនៅក្នុងអំឡុងរបបនេះ និងផលប៉ះពាល់នៃសង្គ្រាមស៊ីវិលដែលបន្តកើតមាន[៥២]។ ទោះបីជាយ៉ាងណាក៏ដោយ ផ្អែកតាមអង្គហេតុជាក់ស្តែង សម្ភារៈឯកសារនេះមិនអាចឲ្យចៅក្រមអន្តរជាតិសន្និដ្ឋានបានថា ការចោទប្រកាន់ ឬការស៊ើបសួរណាមួយ មិនអាចនឹងធ្វើបាននៅក្នុងអំឡុងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ នោះទេ។ ផ្ទុយទៅវិញ មានភស្តុតាងបង្ហាញថា ចាប់ពីឆ្នាំ១៩៧៩មក ច្បាប់ និងក្រឹត្យ-ច្បាប់នានាត្រូវបានអនុម័តជាបន្តបន្ទាប់[៥៣]។ ឧទាហរណ៍ នៅឆ្នាំ១៩៨០ និងឆ្នាំ១៩៨២ ក្រឹត្យ-ច្បាប់នានាត្រូវបានចេញពាក់ព័ន្ធនឹងការរៀបចំតុលាការ[៥៤] និងនៅឆ្នាំ១៩៨៥ និងឆ្នាំ១៩៨៧ ពាក់ព័ន្ធនឹងការបង្កើតតុលាការកំពូល[៥៥]។ ច្បាប់ព្រហ្មទណ្ឌជាក់លាក់មួយក៏ត្រូវបានចេញផងដែរ តាមរយៈ ក្រឹត្យ-ច្បាប់ នៅឆ្នាំ១៩៨០ ដែលមានអានុភាពប្រតិសកម្មចាប់ពីថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩[៥៦]។

---

[៥២] *សូមមើល*ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ កថាខណ្ឌ១៦៦។ ប្រតិចារឹក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ទំព័រ៣៤-៣៦។ ប្រតិចារឹក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ទំព័រ៧២។ *សូមមើលផងដែរ* អង្គការសហប្រជាជាតិ *របាយការណ៍ស្តីពីក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជាដែលបង្កើតឡើងអនុលោមតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 52/135* (A/53/850-S/1999/231) ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ កថាខណ្ឌ៤៣ (ឯកសារ E9/5.13 និង E9/7.26)។ (កត់សម្គាល់អំពីតម្រូវការដើម្បីបង្កើតប្រព័ន្ធតុលាការឡើងវិញ និងដើម្បីអប់រំមេធាវី រដ្ឋអាជ្ញា និងចៅក្រម)។

[៥៣] *សូមមើលឧទាហរណ៍* ក្រឹត្យ-ច្បាប់លេខ១ ស្តីអំពីការបង្កើតតុលាការប្រជាជនបដិវត្តន៍ (ខេត្តនិងរាជធានី) (ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨០) (ឯកសារ E9/9.3) (ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់ទោស "បន ប៉ុល ពត-អៀង សារី"។

[៥៤] ក្រឹត្យ-ច្បាប់លេខ១ ស្តីអំពីការបង្កើតតុលាការប្រជាជនបដិវត្តន៍ (ខេត្តនានា និងរាជធានី) (ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨០)។ ឯកសារ E9/9.3, ERN (ភាសាអង់គ្លេស) 00336567-00336569។ ក្រឹត្យ-ច្បាប់ លេខ១ ស្តីអំពីការបង្កើតតុលាការប្រជាជនបដិវត្ត (ខេត្តនានា និងរាជធានី) (ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨២)។ ក្រឹត្យ-ច្បាប់ លេខ២ ច្បាប់ស្តីពីការចាត់តាំងតុលាការ និងអយ្យការ (ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២)។

[៥៥] ក្រឹត្យ-ច្បាប់លេខ២៨ ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨៥)។ ក្រឹត្យ-ច្បាប់ លេខ៣៤ ស្តីពីការចាត់តាំង និងសកម្មភាពរបស់តុលាការប្រជាជាតិកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល (ថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៨៧)។

[៥៦] ក្រឹត្យ-ច្បាប់ លេខ២ ស្តីពីការផ្តន្ទាទោសក្បត់បដិវត្តន៍ និងបណ្តាទោសប្រព្រឹត្តបទល្មើសផ្សេងៗទៀត (ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០) E9/9.4។

៣៣. ទោះបីជាសង្គ្រាមស៊ីវិល និងការគ្រប់គ្រងដ៏មានប្រសិទ្ធភាព របស់ខ្មែរក្រហមទៅលើតំបន់មួយចំនួនក្នុងប្រទេស ដែលអាចបង្ហាញនូវឧបសគ្គយ៉ាងពិតប្រាកដនៅក្នុងការផ្តួចផ្តើមការចោទប្រកាន់ ឬការស៊ើបសួររបស់តុលាការក៏ដោយ ក៏ចៅក្រមអន្តរជាតិសន្និដ្ឋានថាការស៊ើបសួរ ឬការចោទប្រកាន់មិនបានបង្អាក់គ្រប់កន្លែងនៅក្នុងប្រទេសនោះទេ។ ចៅក្រមអន្តរជាតិយល់ឃើញថា សម្ភារៈឯកសារជាច្រើនដែលត្រូវបានរកឃើញនៅមន្ទីរស២១ ត្រូវបានមន្ទីរស២១ និងក្រោយមកមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូល និងរក្សាទុកភ្លាមៗ ក្រោយពេលដែលជនជាប់ចោទបានចាកចេញពីគុកនោះនៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[៥៧]។ អ្នកស្រាវជ្រាវ និងអ្នកនិពន្ធ បានប្រើប្រាស់សម្ភារៈឯកសារទាំងនោះចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៨០ ហើយអ្នកជំនាញ CHANDLER ក៏បានផ្តល់សក្ខីកម្មដោយផ្អែកលើសម្ភារៈឯកសារទាំងនេះដែរ។ហេតុដូច្នេះ សម្ភារៈឯកសារទាំងនេះអាចយកមកប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការស៊ើបអង្កេត និងជំនុំជម្រះក្នុងអំឡុងពេលនោះ។

៣៤. លើសពីនេះទៀត សហព្រះរាជអាជ្ញាស្វែងរកការព្យួរ ឬផ្តាច់ចិរវេលានៃអាជ្ញាយុកាលរហូតដល់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ជាកាលបរិច្ឆេទនៃការបង្កើតព្រះរាជាណាចក្រកម្ពុជា ដោយការប្រកាសនូវរដ្ឋធម្មនុញ្ញរបស់ខ្លួន[៥៨]។ ទោះបីជាមានការផ្លាស់ប្តូរដ៏គួរឱ្យកត់សម្គាល់ នៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏វាមិនមានភស្តុតាងច្បាស់លាស់បង្ហាញឱ្យឃើញថា ការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ បានស្តារនូវប្រព័ន្ធយុត្តិធម៌កម្ពុជាឱ្យមានសមត្ថភាពដោយសត្យានុម័ត ដើម្បីស៊ើបសួរ ឬចោទប្រកាន់នោះទេ ឬបានលុបបំបាត់នូវភាពទន់ខ្សោយដែលមានលក្ខណៈជាប្រព័ន្ធ ដែលគេសង្កេតឃើញមានពីមុនៗ ដែលភាគច្រើននៃបញ្ហាទាំងនោះ បន្តមានហួសឆ្នាំ១៩៩៣ ទៅទៀត[៥៩]។

---

[៥៧] ប្រតិចារឹក (David Chandler) ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ ទំព័រ៥។ *សូមមើលផងដែរ* បុព្វកថារបស់សៀវភៅដែលមានចំណងជើង "សំឡេងពីមន្ទីរស២១" និពន្ធដោយ Chandler ឯកសារ E3/427 ERN 00192674។

[៥៨] សេចក្តីសន្និដ្ឋានរបស់ ក.ស.ព កថាខណ្ឌ៣៦។ ធម្មនុញ្ញនេះ រួមបញ្ចូលគោលការណ៍ដែលមានចែងក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១។

[៥៩] *សូមមើល* លិខិតចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ ពីរាជរដ្ឋាភិបាលកម្ពុជា ស្នើសុំជំនួយរបស់អង្គការសហប្រជាជាតិដើម្បីស៊ើបសួរ និងចោទប្រកាន់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារមូលហេតុដែលថាប្រទេសកម្ពុជាខ្វះខាតធនធាន ឬជំនាញ ដើម្បីរៀបចំការជំនុំជម្រះនោះ។ ឯកសាររបស់អង្គការសហប្រជាជាតិ A/51/930-S/1997/488 (ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៧)។ ឯកសារអង្គការសហប្រជាជាតិ (ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៨) កថាខណ្ឌ១៦។

៣៥. ផ្អែកតាមភស្តុតាងដែលបានដាក់នូវចំពោះមុខអង្គជំនុំជម្រះ ចៅក្រមអន្តរជាតិអាចធ្វើការសន្និដ្ឋានបានថា ប្រព័ន្ធច្បាប់កម្ពុជាមិនមែនមិនមានសមត្ថភាពដោយសត្យានុម័ត ក្នុងការផ្តើមការស៊ើបសួរ ឬការចោទប្រកាន់មុនឆ្នាំ១៩៩៣នោះទេ និងថា ថិរវេលានៃអាជ្ញាយុកាលដែលអាចយកមកអនុវត្ត មិនត្រូវបានចាត់ទុកថាព្យួរ ឬផ្អាច់ រហូតដល់ឆ្នាំ១៩៩៣ ឡើយ។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ថិរវេលានៃអាជ្ញាយុកាលនេះបានផុតរលត់នៅមុនថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ និងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ដែលកាលបរិច្ឆេទនេះ មាត្រា៣ និងមាត្រា ៣ថ្មី នៃច្បាប់ អ.វ.ត.ក បានពន្យារថិរវេលានៃអាជ្ញាយុកាល។

**ខ. ផលប៉ះពាល់នៃបទដ្ឋានច្បាប់ជាតិ និងអន្តរជាតិដែលអាចយកមកអនុវត្ត**

១. <u>មតិយោបល់របស់ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម ធូ មណី</u>

៣៦. យើងជាចៅក្រមកម្ពុជាបានយល់ឃើញពីមុនថា ជនជាប់ចោទអាចត្រូវផ្តន្ទាទោស ពីបទមនុស្សឃាត និងបទទារុណកម្មបាន ដោយសារតែថិរវេលានៃអាជ្ញាយុកាល តាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មិនទាន់ផុតរលត់នៅឡើយទេ នៅពេល អ.វ.ត.ក ចាប់ផ្តើមស៊ើបអង្កេតនៅឆ្នាំ២០០៦ នោះ។ ជាបច្ច័យ ចៅក្រមកម្ពុជាមិនចាំបាច់ពិចារណាមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក ទាក់ទងនឹងសំនួរដែលថា តើថិរវេលានៃអាជ្ញាយុកាលនៃឧក្រិដ្ឋកម្មជាតិដែលត្រូវបានចោទប្រកាន់ ចំពោះជនជាប់ចោទនោះ បានផុតរលត់ទៅហើយ ឬយ៉ាងណានោះទេ។ ដូច្នេះ ចៅក្រមកម្ពុជាមិនចាំបាច់ពិចារណាថា តើមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក ស្របនឹងមាត្រា១៤ និងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដូចដែលតម្រូវដោយមាត្រា៣៣ ថ្មី កថាខណ្ឌ២ នៃច្បាប់ដដែលនេះឡើយ។

៣៧. ចៅក្រមកម្ពុជានៃអង្គជំនុំជម្រះសាលាដំបូង ធ្វើការយោងបន្ថែមទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលផ្នែកពាក់ព័ន្ធនៃសេចក្តីសម្រេចនេះចែងថា[៦០]៖

---

[៦០] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សេចក្តីសម្រេចលេខ ០៤០/០០២/២០០១ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១។ ឯកសារ E9/7.2។

ក្រោយពីបានស្តាប់ របាយការណ៍របស់សមាជិករាយការណ៍ [និង] ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ [ក្រុមប្រឹក្សាធម្មនុញ្ញ] យល់ឃើញថា មាត្រាទី៣ វាក្យខណ្ឌទី២ នៃច្បាប់នេះ បានពន្យារពេលបន្ថែម២០ឆ្នាំទៀត ទៅលើថិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្ម ដែលមាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានកំណត់ត្រឹមតែ១០ឆ្នាំ។ អានុភាពនៃមាត្រា៣ វាក្យខណ្ឌទី២នេះ បានធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ជាសារវន្តមួយ៖ "អប្រតិសកម្មភាព នៃច្បាប់ថ្មីលើបទល្មើស ដែលបានកើតក្នុងអតីតកាល" ដែលប្រទេសកម្ពុជា ក៏ដូចជាអារ្យប្រទេសមួយចំនួនបានទទួលស្គាល់ជាទូទៅក្នុងសម័យមុនឆ្នាំ១៩៧៥ ក៏ដូចជាសម័យក្រោយឆ្នាំ១៩៧៨ ដោយរាប់បញ្ចូលទាំងសម័យអន្តរកាល នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផង។

ប៉ុន្តែកម្ពុជាមិនបានបញ្ជាក់ថា គោលការណ៍ជាសារវ័ន្តនេះ មានតម្លៃស្មើនឹងរដ្ឋធម្មនុញ្ញឡើយ ហេតុដូច្នេះហើយ បានជាសភាធម្មនុញ្ញ... មិនបានបញ្ញត្តពីគោលការណ៍នេះក្នុងមាត្រាណាឡើយ ក្នុងបុព្វកថាក៏មិនមានដែរ។ លើសពីនេះទៅទៀត ទុកជាគោលការណ៍នេះ មានតម្លៃស្មើនឹងអ្វីក៏ដោយ ឬត្រូវបានចារឹកជាលាយលក្ខណ៍អក្សរ ឬក៏គ្មាន ក៏គេត្រូវគោរពគោលការណ៍មួយទៀត "រាល់គោលការណ៍មានសមាសពលពីរ៖ វិធាន និងអញ្ញត្រកម្ម" បើវិធានមានតម្លៃស្មើអ្វី អញ្ញត្រកម្ម ក៏មានតម្លៃដូចគ្នា។ អប្រតិសកម្មភាព ដែលមិនត្រូវបានចែងក្នុងរដ្ឋធម្មនុញ្ញ គេបានឃើញក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ [...]

រួមសេចក្តីទៅ មិនមានឃើញអ្វីប៉ះពាល់ដល់ធម្មនុញ្ញភាពទេ។

៣៨. ផ្អែកតាមសេចក្តីសម្រេចនេះ ចៅក្រមកម្ពុជាកត់សម្គាល់ថា ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចថា ការពន្យារថិរវេលានៃអាជ្ញាយុកាល ដូចមានចែងក្នុងមាត្រា៣ ថ្មី គឺស្របនឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ចៅក្រមកម្ពុជាកត់សម្គាល់បន្ថែមទៀតថា ចៅក្រមកម្ពុជាមិនមានសមត្ថកិច្ចពិនិត្យអំពីភាពត្រឹមត្រូវនៃសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ។

២. <u>មតិយោបល់របស់យើងជាចៅក្រមអន្តរជាតិ ចៅក្រម Cartwright និងចៅក្រម Lavergne</u>

៣៩. មាត្រា៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា អ.វ.ត.ក ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់

ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃ ICCPR។ អាស្រ័យហេតុនេះ បទដ្ឋានអន្តរជាតិ ដែលអាចយកមកអនុវត្តដោយផ្ទាល់ គឺជាទស្សនទាននៃការជំនុំជម្រះមួយប្រកបដោយ យុត្តិធម៌ ដូចដែលមានចែងនៅក្នុងមាត្រា១៤ និង១៥ នៃ ICCPR ដែលកម្ពុជាបានផ្តល់ សច្ចាប័ន និងបានបញ្ចូលបទប្បញ្ញត្តិនេះទៅក្នុងច្បាប់ជាតិ[៦១]។

៤០. មាត្រា១៤ នៃ ICCPR ធានាឱ្យមានការអនុវត្តកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះឱ្យបាន ត្រឹមត្រូវ និងរក្សានូវសិទ្ធិនានារបស់បុគ្គលម្នាក់ៗ រួមមានសិទ្ធិទទួលបានសវនាការ សាធារណៈប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស តាមរយៈតុលាការដែលមានសមត្ថភាព ឯករាជ្យ ឥតលម្អៀង ដែលច្បាប់បានបង្កើតឡើង។

៤១. គោលការណ៍នីត្យានុកូលភាព ដែលរួមបញ្ចូលទាំងការហាមឃាត់ចំពោះការអនុវត្ត ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌនៅក្នុងមាត្រា១៥(១) នៃ ICCPR ហាមឃាត់មិនឱ្យចាត់ ទុកជនណាម្នាក់ថា "ជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើសកម្ម ឬអកម្ម ដែលមិន បានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅពេលដែល បទល្មើសនោះត្រូវបានប្រព្រឹត្ត" ឬការដាក់ទោសធ្ងន់ធ្ងរ ជាងទោសដែលមានជាធរមាន នៅ ពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត។

៤២. ទាំងមាត្រា១៤ និងមាត្រា១៥ នៃ ICCPR មិនបានសំដៅដោយផ្ទាល់ចំពោះថិរវេលានៃ អាជ្ញាយុកាលទេ។ ដូច្នេះ ប្រភពទាំងនេះពុំបានបកស្រាយច្បាស់លាស់អំពីដែនកំណត់នៃ គោលការណ៍ជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលទាក់ទងនឹងការពិចារណាអំពីប្រតិសកម្ម នៃច្បាប់ ឬលុបចោលអាជ្ញាយុកាលនោះទេ។

៤៣. ដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា បទដ្ឋានអន្តរជាតិនៃការជំនុំជម្រះប្រកបដោយ យុត្តិធម៌ដែលអាចអនុវត្តបាន នៅចំពោះមុខ អ.វ.ត.ក មិនផ្ទុយគ្នាទៅនឹងការធ្វើវិសោធនកម្ម ឱ្យមានប្រតិសកម្មចំពោះថិរវេលានៃអាជ្ញាយុកាល ដែលបានធ្វើឡើងដោយអង្គនីតិប្បញ្ញត្តិ នោះទេ។ ប៉ុន្តែចៅក្រមអន្តរជាតិ មិនយល់ស្របជាមួយនឹងសេចក្តីសន្និដ្ឋានរបស់ចៅក្រម កម្ពុជា ដែលថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ២០០១ បង្កើតបានជាសេចក្តី សម្រេចប្រភេទនេះដោយអង្គនីតិប្បញ្ញត្តិកម្ពុជានោះទេ។ ចៅក្រមអន្តរជាតិនឹងពិចារណា

[៦១] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៣១។

បន្ថែមចំពោះសញ្ញាណនៃ "ការពន្យារ" ថិរវេលានៃអាជ្ញាយុកាល ដូចមានចែងនៅក្នុង មាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក។

*(i) ការបកស្រាយអំពី "ការពន្យា" ថិរវេលានៃអាជ្ញាយុកាលនៅក្នុងមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក និងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ២០០១*

៤៤. ទោះបីជាមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក ចែងអំពី "ការពន្យារ" ថិរវេលានៃអាជ្ញាយុកាល ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ក៏ដោយ ក៏អត្ថន័យច្បាស់លាស់នៃ សញ្ញាណនៃពាក្យ "ការពន្យារថិរវេលា" គឺជាការអូសបន្លាយ ឬជាការបន្តថិរវេលាដែល មានស្រាប់។ ដោយសារតែចៅក្រមអន្តរជាតិបានសន្និដ្ឋានថា ថិរវេលានៃអាជ្ញាយុកាលនេះ បានផុតរលត់រួចហើយ មុនពេលអនុម័តមាត្រា៣ ថ្មី អាស្រ័យហេតុនេះថិរវេលានៃ អាជ្ញាយុកាលមិនអាច "ពន្យារ" បានទេ។ ការសន្និដ្ឋាននេះ ស្របគ្នាជាមួយនឹងគោល ការណ៍បកស្រាយទូទៅ ដែលបានគូសបញ្ជាក់នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ដែលថា មិនមានតម្រូវការឲ្យបកស្រាយច្បាប់នោះទេ ប្រសិនបើច្បាប់នោះចែងច្បាស់ លាស់ និងថា បទប្បញ្ញត្តិទាក់ទងនឹងបទឧក្រិដ្ឋនានា ត្រូវតែធ្វើការបកស្រាយយ៉ាង តឹងរ៉ឹង[៦២]។

៤៥. បន្ថែមពីលើនេះ ចៅក្រមអន្តរជាតិអាចសន្និដ្ឋានថា អង្គនីតិប្បញ្ញត្តិកម្ពុជាមិនដែលបង្ហាញ ពីចេតនា ដើម្បីព្យួរថិរវេលានៃអាជ្ញាយុកាល ឬប្រតិសកម្មសិទ្ធិដើម្បីចោទប្រកាន់បទល្មើស ជាតិ ក្រោយពេលផុតរលត់អាជ្ញាយុកាលទាល់តែសោះ។ ផ្អែកតាមមូលហេតុដូចបាន បង្ហាញខាងក្រោម ការបកស្រាយបែបនេះ ផ្ទុយទៅនឹងច្បាប់កម្ពុជាដែលក្នុងនោះ មាត្រា៧ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានចែងថា "កាលណាបណ្ដឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្ដើមបានទៀតទេ ឬត្រូវតែបញ្ឈប់"[៦៣]។

---

[៦២] *សូមមើល* មាត្រា៥ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E180/1 ៖ "ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬ ប្រព្រឹត្តតាមសទិសភាពបានឡើយ"។

[៦៣] បទប្បញ្ញត្តិដូចគ្នានេះ ចែងពីការផុតរលត់ថិរវេលានៃអាជ្ញាយុកាល ថាជាហេតុផលមួយក្នុងចំណោមហេតុផល ទាំងឡាយសម្រាប់ការរលត់ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌ។

៤៦. នៅក្នុងសេចក្ដីសម្រេចចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានសម្រេចថា សញ្ញាណនៃពាក្យ "ការពន្យារចិរវេលា" ដូចមានចែងនៅក្នុងមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក មិនរំលោភរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ដោយមិនបានចង្អុលបង្ហាញអំពីសញ្ញាណនៃពាក្យ "ការពន្យារចិរវេលា" ដែលត្រូវបកស្រាយលើសពីអត្ថន័យធម្មតារបស់វានោះទេ។ នៅក្នុងសំអាងហេតុរបស់ខ្លួន ក្រុមប្រឹក្សាធម្មនុញ្ញ គ្រាន់តែកត់សម្គាល់ថា មាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក ប៉ះពាល់ដល់គោលការណ៍ "ជាមូលដ្ឋាន" នៃអប្រតិសកម្មភាពនៃច្បាប់ព្រហ្មទណ្ឌ ប៉ុន្តែមិនបានធ្វើការសម្រេចបន្ថែមទៀត ចំពោះផលប៉ះពាល់នៃគោលការណ៍នេះទេ[៦៤]។

៤៧. គ្មានការជំទាស់ចំពោះការលើកឡើងថា ចិរវេលានៃអាជ្ញាយុកាលអាចត្រូវបានពន្យារមុនពេលផុតរលត់ ដោយបទប្បញ្ញត្តិច្បាប់ដែលមានចែងច្បាស់លាស់ ឬក៏នៅក្នុងកាលៈទេសៈលើកលែងមួយចំនួន ដោយចិរវេលានៃអាជ្ញាយុកាលអាចត្រូវបានប្រកាសថា បានព្យួរនៅក្នុងអំឡុងពេលដែលថា ការចោទប្រកាន់មិនអាចធ្វើទៅបាន ដោយមូលហេតុដែលមានលក្ខណៈសត្យានុម័តនោះ។ ទោះបីជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ណាស់ដែលថា ការពន្យារចិរវេលា ឬការព្យួរចិរវេលានៃអាជ្ញាយុកាលត្រូវតែផ្ដល់ឲ្យ ប្រសិនបើការពន្យារ ឬការព្យួរនេះ មិនផ្ទុយនឹងគោលការណ៍អប្រតិសកម្មភាព។ ចៅក្រមអន្តរជាតិយល់ឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញមិនបានលើកឡើងឲ្យច្បាស់ថា ច្បាប់ អ.វ.ត.ក មានចេតនាផ្ដល់នូវការព្យួរឲ្យមានប្រតិសកម្មចំពោះចិរវេលានៃអាជ្ញាយុកាលដែលយកមកអនុវត្ត ឬបង្កើតសាជាថ្មីនូវសិទ្ធិចោទប្រកាន់ បន្ទាប់ពីការផុតរលត់ចិរវេលានៃអាជ្ញាយុកាលនោះទេ។

៤៨. នៅក្នុងការពិចារណាអំពីចិរវេលានៃអាជ្ញាយុកាល នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងអង្គហេតុដែលថា អវត្តមាននៃកិច្ចណាមួយនៃការស៊ើបសួរ ឬការចោទប្រកាន់មុនឆ្នាំ ១៩៨៩ នឹងរារាំងដល់ការចោទប្រកាន់នោះ របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា[៦៥] បានបង្ហាញថា៖

---

[៦៤] សូមមើលកថាខណ្ឌ ៣៧។

[៦៥] ក្រុមអ្នកជំនាញត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៨ អនុលោមតាមសេចក្ដីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥ និងបានផ្ដល់អនុសាសន៍ថា ដើម្បីនាំមេដឹកនាំខ្មែរក្រហមមកកាត់ទោសបាន ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ពួកគេ មិនត្រូវពិចារណាត្រឹមតែក្នុងច្បាប់អន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែត្រូវពិចារណានៅក្នុងច្បាប់ជាតិផងដែរ។ *សូមមើល* ឯកសារអង្គការសហប្រជាជាតិលេខ A/53/850-S/1999/231 ឧបសម្ព័ន្ធ ("របាយការណ៍របស់ក្រុម

ផ្នែកតាមយុត្តិសាស្ត្រនៅប្រទេសអឺរ៉ុប ដែលបានផ្តន្ទាទោសពួក Nazi ដែលប្រព្រឹត្តបទឧក្រិដ្ឋ ក្រោយពេលការផុតរលត់ចិរវេលានៃអាជ្ញាយុកាល ជាពិសេសប្រទេសអាល្លឺម៉ង់ និងប្រទេសបារាំង នៅទសវត្សរ៍ឆ្នាំ១៩៦០ និងទសវត្សរ៍ឆ្នាំ១៩៨០។ ជម្រើសផ្សេងទៀតនៅតែមានសម្រាប់ប្រទេសកម្ពុជា។ ជម្រើសទីមួយ រដ្ឋសភាអាចលុបចោលចិរវេលានៃអាជ្ញាយុកាល ទោះបីជា ចិរវេលានៃអាជ្ញាយុកាល បានផុតរលត់ទៅហើយក៏ដោយ។ ជម្រើសទីពីរ រដ្ឋសភាអាចព្យួរការអនុវត្តចិរវេលានៃអាជ្ញាយុកាលចាប់ពីឆ្នាំ១៩៧៥ រហូតមកទល់ពេលបច្ចុប្បន្ន ដោយមូលហេតុថា តុលាការមិនទាន់ដំណើរការពេញលេញនៅឡើយទេ[៦៦]។

៤៩. ចៅក្រមអន្តរជាតិទទួលស្គាល់ថា នៅឆ្នាំ២០០១ អង្គនីតិប្បញ្ញត្តិរបស់កម្ពុជាអាចធ្លាប់មានចេតនាក្នុងលក្ខខណ្ឌស្រដៀងគ្នាក្នុងការផ្តល់អំណាចដល់ អ.វ.ត.ក ដើម្បីជំនុំជម្រះបទឧក្រិដ្ឋតាមច្បាប់ជាតិ រួមទាំងការបង្កើតសាជាថ្មីនូវអំណាចឲ្យចោទប្រកាន់ ក្រោយពេលផុតរលត់ចិរវេលានៃអាជ្ញាយុកាល។ ក៏ប៉ុន្តែ ដើម្បីធ្វើដូច្នេះបាន យ៉ាងហោចណាស់ ក៏ត្រូវមានច្បាប់មួយដែលច្បាស់លាស់ និងល្អិតល្អន់។ លើសពីនេះ ការបង្កើតសាជាថ្មីនូវសិទ្ធិចោទប្រកាន់ ក៏ចាំបាច់ត្រូវធានាឲ្យប្រាកដថា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ស្របទៅនឹងបទដ្ឋានជាតិ ឬអន្តរជាតិ ពោលគឺ បទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងមាត្រា១៤ ឬមាត្រា១៥ នៃ ICCPR។ ដូច្នេះ ចៅក្រមអន្តរជាតិនឹងពិចារណាថា តើវាផ្ទុយទៅនឹងបទដ្ឋានទាំងនេះដែរ ឬទេ ប្រសិនបើមានការបកស្រាយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ២០០១ ថាជាការបង្កើតសាជាថ្មីនូវសិទ្ធិចោទប្រកាន់នោះ។

(ii) ***តើ "ការពន្យារចិរវេលា" នៃអាជ្ញាយុកាលក្រោយពេលផុតរលត់ស្របជាមួយនឹងបទដ្ឋានជាតិ និងអន្តរជាតិជាធរមានដែរ ឬទេ?***

---

អ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបង្កើតឡើងអនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ៥២/១៣៥" ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩) កថាខណ្ឌ៨៤៖ "បទឧក្រិដ្ឋផ្នែកតាមច្បាប់ជាតិ នឹងខ្វះខាតនូវធាតុផ្សំពិសេសរបស់ឧក្រិដ្ឋកម្មអន្តរជាតិជាច្រើន ដូច្នេះបទឧក្រិដ្ឋនេះងាយស្រួលនឹងមានធាតុផ្សំមកបង្ហាញណាស់"។

[៦៦] របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបង្កើតឡើងដោយអនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ កថាខណ្ឌ៩០។

## ក. ការអនុវត្តបទដ្ឋានជាតិ និងអន្តរជាតិ

៥០. ដោយសារតែមាត្រា១៤ និងមាត្រា១៥ នៃ ICCPR មិនបានសំដៅដោយផ្ទាល់ចំពោះថិរវេលានៃអាជ្ញាយុកាល ដូចនេះ "ការពន្យាថិរវេលា" នៃអាជ្ញាយុកាលដោយច្បាប់ដែលរួមបញ្ចូលទាំងការបង្កើតសារជាថ្មីនូវសិទ្ធិចោទប្រកាន់ ក្រោយពេលផុតរលត់ថិរវេលានៃអាជ្ញាយុកាលនោះ អាចត្រូវបានចាត់ទុកថាអាចធ្វើទៅបានស្របតាមប្រភពទាំងនេះ ពីព្រោះថាវាមិនបានរំលោភភាសាសាមញ្ញនៃមាត្រា១៥(១) នៃ ICCPR។ ប៉ុន្តែ បើផ្អែកតាមសញ្ញាណនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ គោលការណ៍សុវត្ថិភាពគតិយុត្ត និងគោលការណ៍ជំនុំជម្រះដោយយុត្តិធម៌ ច្បាប់ជាតិមួយចំនួន និងយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប បានយល់ឃើញថាការពន្យារថិរវេលានៃអាជ្ញាយុកាល អាចធ្វើទៅបានតែក្នុងករណីដែលថិរវេលានៃអាជ្ញាយុកាលនោះ មិនទាន់ផុតរលត់ប៉ុណ្ណោះ[៦៧]។ នៅក្នុងសេចក្ដីសម្រេចក្នុងរឿងក្ដី *Kononov* តុលាការសិទ្ធិមនុស្សអឺរ៉ុបបានបកស្រាយមាត្រា៧ នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប ក្នុងគោលបំណងដើម្បីទប់ស្កាត់មិនឱ្យធ្វើបណ្ដឹងអាជ្ញាជាថ្មីចំពោះបទឧក្រិដ្ឋជាតិដែលបានផុតរលត់ថិរវេលានៃអាជ្ញាយុកាល[៦៨]។

---

[៦៧] *សូមមើល* ឧទាហរណ៍បទប្បញ្ញត្តិនៃមាត្រា១១២ កថាខណ្ឌ២ វាក្យខណ្ឌ៤ នៃក្រមព្រហ្មទណ្ឌរបស់ប្រទេសបារាំងចែងថា៖ *"បទប្បញ្ញត្តិខាងក្រោមនេះ អនុវត្តភ្លាមៗលើការទប់ស្កាត់បទល្មើសដែលត្រូវបានប្រព្រឹត្តមុនពេលបទប្បញ្ញត្តិនោះចូលជាធរមាន៖ ...វាក្យខណ្ឌ៤ នៅពេលថិរវេលានៃអាជ្ញាយុកាលមិនទាន់ផុតរលត់ ច្បាប់គ្រប់ដណ្ដប់លើថិរវេលានៃអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា [...]"*។ ទាក់ទងនឹងគោលការណ៍ នៃភាពអាចប្រមើលមើលដឹងថាជាបទល្មើស និងការដឹងថាមានច្បាប់ចែង នៃបទប្បញ្ញត្តិព្រហ្មទណ្ឌ *សូមមើល រឿងក្ដី* Coëme a.o. *តទល់នឹង ប្រទេសបែលហ្សិក* កថាខណ្ឌ១៤៩។

[៦៨] *រឿងក្ដី* Kononov *តទល់នឹង ប្រទេសឡាតវី (បណ្ដឹងលេខ 36376/04)* សេចក្ដីសម្រេចរបស់តុលាការ ECtHR ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ១៤៤-១៤៦ (កត់សម្គាល់ថា ទោះបីជាសំអាងហេតុពីមុនទាក់ទងនឹងមាត្រា៧ នៃអនុសញ្ញា (ដែលឆ្លុះបញ្ចាំងពីមាត្រា១៥ នៃ ICCPR) មិនបានហាមឃាត់នូវការពន្យារថិរវេលានៃអាជ្ញាយុកាលដែលមិនទាន់ផុតរលត់ ក៏បទប្បញ្ញត្តិនេះពិតជាបានទប់ស្កាត់ការបង្កើតឡើងនូវលទ្ធភាពផ្ដន្ទាទោសបទល្មើសក្រោយពីផុតថិរវេលានៃអាជ្ញាយុកាលហើយ។ ទោះបីជាទទួលស្គាល់ថា ចាប់តាំងពីការស្ដារឡើងវិញនូវឯករាជ្យភាពរបស់ប្រទេសឡាតវី នៅឆ្នាំ១៩៩១ ដែលអាជ្ញាធរនៃរដ្ឋនេះ អាចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនទាំងឡាយដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសចន្លោះឆ្នាំ១៩៤០ ដល់ឆ្នាំ១៩៩១។ ការវិនិច្ឆ័យទោសចំពោះបទល្មើសដែលផុតថិរវេលានៃអាជ្ញាយុកាល គឺផ្ទុយនឹងគោលការណ៍នៃការប្រមើលមើលថាជាបទល្មើស ដែលមាននៅក្នុងមាត្រា៧នៃអនុសញ្ញា)។ សំអាងហេតុទាំងនេះមិនត្រូវបានចងកាតព្វកិច្ចដោយសេចក្ដីសម្រេចថ្មីៗនៃរឿងក្ដី Kononov *ទល់នឹងប្រទេសឡាតវី* សាលដីកា

៥១. ការប៉ុនប៉ងបង្កើតសាជាថ្មី នូវសិទ្ធិចោទប្រកាន់ចំពោះបទឧក្រិដ្ឋដែលថិរវេលានៃអាជ្ញាយុកាលបានផុតរលត់ហើយនោះ គឺកើតមានបញ្ហាចម្រូងចម្រាសជាច្រើននៅចំពោះមុខតុលាការថ្នាក់ជាតិមួយចំនួន។ នៅសហរដ្ឋអាមេរិក ច្បាប់មួយដែលពន្យារថិរវេលានៃអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋ ក្រោយពេលដែលថិរវេលានៃអាជ្ញាយុកាលត្រូវបានផុតរលត់ហើយនោះ ត្រូវបានគេរកឃើញថារំលោភរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក នៅពេលដែលច្បាប់មួយនេះបានធ្វើឱ្យរស់ឡើងវិញនូវការចោទប្រកាន់មួយដែលថិរវេលានៃអាជ្ញាយុកាលបានផុតរលត់ទៅហើយ[៦៩]។ ប្រទេសជាច្រើនដទៃទៀតហាក់ដូចជាមានការរារែកនៅក្នុងការអនុវត្តដើម្បីពន្យារថិរវេលានៃអាជ្ញាយុកាល បន្ទាប់ពីថិរវេលានៃអាជ្ញាយុកាលនោះបានផុតរលត់[៧០]។

## ខ. អំពីច្បាប់កម្ពុជាដែលមានជាបន្តបន្ទាប់

៥២. ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា បទមនុស្សឃាត និងបទទារុណកម្មតាមច្បាប់ជាតិដែលអាចផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានផុតរលត់ដោយសារការអនុវត្ត

---

របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ECtHR (no. 36376/04) ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ២២៨-២៣៣។

[៦៩] *សូមមើល* Stogner *តទល់នឹង រដ្ឋកាលីហ្វញ៉ា* 539 U.S. 607 (២០០៣) ឯកសារលេខ E9/8.4។ ប៉ុន្តែមានមតិជំទាស់យ៉ាងខ្លាំងមួយ ដែលលើកសំអាងថា "ច្បាប់ដែលមិនបានផ្លាស់ប្តូរនិយមន័យបទល្មើស ប៉ុន្តែគ្រាន់តែ "កែប្រែការចោទប្រកាន់ដែលផុតអាជ្ញាយុកាល គឺមិនស្ថិតនៅក្នុងនិយមន័យនៃច្បាប់ប្រតិសកម្មដែលទទួលស្គាល់នោះទេ" (*Stogner ទល់នឹង រដ្ឋកាលីហ្វញ៉ា*, 539 U.S. 639 (2003) ឯកសារ E9/8.4)។

[៧០] ឧទាហរណ៍ ច្បាប់ធម្មនុញ្ញអាល្លឺម៉ង់ បានហាមឃាត់ចំពោះការពន្យារថិរវេលាបែបនេះ (តុលាការធម្មនុញ្ញអាល្លឺម៉ង់ BVerfGE 25, 269 (2 BvL 15, 23/68))។ ប្រទេសហុងគ្រី ក៏បានបដិសេធការពន្យារថិរវេលានៃអាជ្ញាយុកាលដោយសារតែការហាមឃាត់ចំពោះច្បាប់ប្រតិសកម្ម (សូមមើលតុលាការធម្មនុញ្ញហុងគ្រី។ សេចក្តីសម្រេចស្តីពីថិរវេលានៃអាជ្ញាយុកាល លេខ 2086/A/1991/14 ថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៩២ បកប្រែជាភាសាអង់គ្លេស និងបទអត្ថាធិប្បាយនៅក្នុងព្រឹត្តិបត្រស្រាវជ្រាវ Journal of Constitutional Law in Eastern and Central Europe 129-157 (1994))។ ប្រទេសផ្សេងៗជាច្រើន បានលុបចោលថិរវេលានៃអាជ្ញាយុកាលនៃបទមនុស្សឃាត និងបទឧក្រិដ្ឋធ្ងន់ធ្ងរផ្សេងទៀត ប៉ុន្តែគ្រាន់តែអនុវត្តច្បាប់ថ្មីនានា ដើម្បីជៀសវាងការចោទប្រកាន់អំពីប្រតិសកម្មនៃច្បាប់តែប៉ុណ្ណោះ (សូមមើល ឧទាហរណ៍ នៅក្នុងប្រទេសហូឡង់, Wet van 16 november 2005 tot wijziging van het Wetboek van Strafrecht in verband met het vervallen van de verjaringstermijn voor de vervolging van moord en enkele andere misdrijven alsmede enige aanpassingen van de regeling van de verjaring en de stuiting van de verjaring en de regeling van de strafverjaringstermijn, Artikel III. Stb. 2005, 595, 13 December 2005 ចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ និងនៅក្នុងប្រទេសអាល្លឺម៉ង់ Einfuehrungsgesetz zum StGB (Introduction Code to the Criminal Code) មាត្រា៣១៥ និង៣១៥ក)។

ថិរវេលានៃអាជ្ញាយុកាលតាមមាត្រា១០៩នៃក្រមនេះ មុនពេលការអនុម័តមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក។ ចៅក្រមអន្តរជាតិបានកត់សម្គាល់បន្ថែមថា វិសោធនកម្មច្បាប់នាពេលថ្មីៗនេះ ទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាល អង្គនីតិប្បញ្ញត្តិកម្ពុជាបានប្រកាន់យកការបកស្រាយទូលំទូលាយ និងហ្មត់ចត់ចំពោះការហាមឃាត់លើការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលមានប្រតិសកម្ម។ ជាក់ស្តែង ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដែលបានបង្កើតឱ្យមានថិរវេលានៃអាជ្ញាយុកាលវែងជាងមុន ចែងក្នុងមាត្រា៦១០ ថា "អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា [...] ចំពោះបទល្មើស ដែលត្រូវបានប្រព្រឹត្តនៅមុនក្រមនេះចូលជាធរមាន ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ចាស់"។ មាត្រា៧ នៃក្រមនេះចែងបន្ថែមទៀតថា "កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់"[៧១]។

៩៣. ក្នុងលក្ខខណ្ឌទូទៅ ការហាមឃាត់មិនឱ្យមានការអនុវត្តប្រតិសកម្មចំពោះច្បាប់ព្រហ្មទណ្ឌ គឺដើម្បីការពារនូវតម្លៃនៃសុវត្ថិភាពគតិយុត្តិ និងធានារក្សាការអនុវត្តនូវគោលការណ៍អនាគតិ និងសត្យានុម័តរបស់នីតិរដ្ឋ។ ការបកស្រាយមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក ដែលអនុញ្ញាតឱ្យបង្កើតសាជាថ្មីនូវសិទ្ធិចោទប្រកាន់ចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិ លើបុគ្គលមួយចំនួនតូច ក្រោយពេលថិរវេលានៃអាជ្ញាយុកាលបានផុតរលត់ អាចត្រូវបានគេយល់ឃើញថា ជាការរំលោភទៅលើគោលការណ៍អនាគតិ និងសត្យានុម័ត[៧២]។

---

[៧១] *ដូចខាងលើ* ជើងទំព័រលេខ១៤។ បទប្បញ្ញត្តិដូចគ្នាចាត់ទុកយ៉ាងច្បាស់ចំពោះការផុតរលត់ថិរវេលានៃអាជ្ញាយុកាលថាជាមូលហេតុមួយក្នុងចំណោមមូលហេតុទាំងឡាយសម្រាប់រំលត់ការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ។

[៧២] *សូមមើលឧទាហរណ៍* ការធានារបស់រដ្ឋធម្មនុញ្ញអំពីភាពស្មើគ្នាចំពោះមុខច្បាប់នៅក្នុងមាត្រា៣១(២) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ អាចនឹងសម្រេចអំពីចំណាត់ការផ្សេងគ្នាចំពោះជនជាប់ចោទទាក់ទងនឹងការវិនិច្ឆ័យទោសបទឧក្រិដ្ឋតាមច្បាប់ជាតិ។ បទប្បញ្ញត្តិនេះចែងថា៖ "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់"។ ទាក់ទងនឹងការពិចារណាផ្សេងគ្នាទៅលើការវិនិច្ឆ័យទោសចំពោះបទល្មើសអន្តរជាតិ *សូមមើលសំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជសង រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង*នៃ អ.វ.ត.ក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ផ្នែក១.៤.២។ ដូចដែលបានកត់សម្គាល់ អង្គនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជាមានឱកាសជាច្រើនដងចាប់តាំងពីឆ្នាំ១៩៧៩ (ពោលគឺនៅឆ្នាំ១៩៩២ និងឆ្នាំ២០០៧) ដើម្បីបញ្ជាក់អំពីផលវិបាកផ្នែកច្បាប់ដែលបណ្តាលមកពីរបបកម្ពុជាប្រជាធិបតេយ្យ មកលើប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជា ប៉ុន្តែអង្គនីតិប្បញ្ញត្តិមិនប្រើឱកាសណាមួយដើម្បីប្រកាសថា ថិរវេលានៃអាជ្ញាយុកាលដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានផ្អាក់ ឬព្យួរនៅក្នុងចន្លោះពីឆ្នាំ១៩៧៩ រហូតដល់ ១៩៩៣ ឬមិនបានលើកឡើងអំពីការបង្កើតឱ្យមានឡើងវិញនូវសិទ្ធិកាត់សេចក្តីបទឧក្រិដ្ឋផ្នែកតាមច្បាប់ជាតិ ដែលបទ

៥៤. ជាសរុបមក ចៅក្រមអន្តរជាតិយល់ឃើញថា បញ្ហាដែលកើតឡើងនៅក្នុងបរិបទបច្ចុប្បន្ន គឺមិនត្រឹមត្រូវតាមច្បាប់ ក្នុងការចោទប្រកាន់អំពីបទមនុស្សឃាត និងបទទារុណកម្មទេ (ដែលបទល្មើសទាំងពីរនេះត្រូវបានផ្តន្ទាទោសជាសកលនៅក្នុងឧក្រិដ្ឋកម្មអន្តរជាតិ) ប៉ុន្តែ បញ្ហាគឺថា តើយុត្តាធិការដែលមាននេះអាចជំនុំជម្រះបទល្មើសប្រហាក់ប្រហែលទៅនឹង ឧក្រិដ្ឋកម្មជាតិដោយផ្អែកលើមូលដ្ឋាននៃក្របខណ្ឌច្បាប់ជាតិបានដែរឬទេ។ ដំបូងបង្អស់ គឺបញ្ហានៃការបង្កើតច្បាប់ជាតិដែលពាក់ព័ន្ធ។ ផ្អែកតាមសម្អាងហេតុខាងលើ ចៅក្រម អន្តរជាតិយល់ឃើញថា ច្បាប់នេះចែងមិនមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីចោទប្រកាន់អំពី បទឧក្រិដ្ឋទាំងនេះនៅចំពោះមុខ អ.វ.ត.ក ទេ។ លើសពីនេះទៀត គ្មានបទប្បញ្ញត្តិណា មួយនៃច្បាប់ជាតិ ឬអន្តរជាតិ ដែលគាំទ្រដល់ការបកស្រាយមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក ដែលថាអាចអនុញ្ញាតឱ្យបង្កើតសាជាថ្មីនូវសិទ្ធិចោទប្រកាន់លើជនជាប់ចោទ ចំពោះបទឧក្រិដ្ឋទាំងនេះទេ។

៥៥. ដោយសារតែមានភាពត្រួតគ្នារវាងធាតុផ្សំនៃបទឧក្រិដ្ឋជាតិ និងបទឧក្រិដ្ឋអន្តរជាតិ ការរកឃើញនេះ មិនមានផលប៉ះពាល់ដល់ការវាយតម្លៃរបស់អង្គជំនុំជម្រះចំពោះការទទួល ខុសត្រូវព្រហ្មទណ្ឌទាំងស្រុងរបស់ជនជាប់ចោទ ឬការផ្តន្ទាទោសជាចុងក្រោយនោះទេ[៧៣]។

---

ឧក្រិដ្ឋទាំងនោះបានផុតចិរវេលានៃអាជ្ញាយុកាល។ *សូមមើលបន្ថែម* បុព្វកថារបស់ច្បាប់អ៊ុនតាក់ឆ្នាំ១៩៩២ ដែល ក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានកត់សម្គាល់យ៉ាងច្បាស់ថា "ដោយមានកង្វល់ថា បណ្តារចនាសម្ព័ន្ធ ច្បាប់ និងស្ថាប័ន តុលាការនៅប្រទេសកម្ពុជា មិនបំពេញឱ្យបានពេញលេញតាមការតម្រូវរបស់កិច្ចព្រមព្រៀងប៉ារីស ព្រមទាំងពេលខ្លះ មានការខ្វះខាតមួយផ្នែក ឬពុំទាន់មានអ្វីទាល់តែសោះ ហើយបើតាមការពិនិត្យពិច័យ គឺមិនសមស្របដើម្បីធានាឱ្យ មានរបៀបរៀបរយ និងសិទ្ធិមនុស្សនៅតាមទីកន្លែងនានាជាច្រើនក្នុងដែនដី" និង "ដោយទទួលស្គាល់ថា ការទាំងនេះ ត្រូវនៅក្រោមការទទួលខុសត្រូវរបស់អ៊ុនតាក់ ដើម្បីសម្រួលការរៀបចំរចនាសម្ព័ន្ធទាំងឡាយ ច្បាប់ និងស្ថាប័ន តុលាការ នៅកន្លែងណាដែលខ្វះខាតហើយជួយកែលម្អ កន្លែងណាដែលមានរួចហើយ ដើម្បីឱ្យសមស្របតាមការ តម្រូវចាំបាច់នៃកិច្ចព្រមព្រៀង"។ *សូមមើលខាងលើផងដែរ* កថាខណ្ឌ១៣ (កត់សម្គាល់ថា មាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក បានពន្យារចិរវេលានៃអាជ្ញាយុកាលចំនួនពីរលើក។ លើកទីមួយ ចិរវេលានៃអាជ្ញាយុកាលត្រូវបានពន្យារ បន្ថែមចំនួន២០ឆ្នាំ និងក្រោយមកអាជ្ញាយុកាលត្រូវបានសរុបពន្យារបន្ថែមចំនួន៣០ឆ្នាំ)។ ការពន្យារចិរវេលានៃ អាជ្ញាយុកាលបែបនេះ មិនត្រូវបានគេផ្តល់នូវការពន្យល់ ឬសនិទានភាពជាផ្លូវការណាមួយទេ។

[៧៣] សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជសដ រឿងក្តី *កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* សាលក្រមរបស់ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ផ្នែក ៣ និងផ្នែកសម្រេចសេចក្តី។

00573326



## IV. សេចក្តីសម្រេច

៥៦. មាត្រា១៤ នៃច្បាប់ អ.វ.ត.ក ចែងថា "ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង តម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច"។ ដោយសារពុំមានសំឡេងបោះឆ្នោតគាំទ្រភាគច្រើនតាមច្បាប់តម្រូវ អង្គជំនុំជម្រះសាលាដំបូងមិនអាចពិចារណាអំពីពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទចំពោះបទឧក្រិដ្ឋជាតិបានទេ។ ហេតុដូច្នេះ ការដែលចៅក្រមមិនអាចរកសំឡេងភាគច្រើនតាមច្បាប់តម្រូវបាននោះ គឺបង្កើតជាឧបសគ្គក្នុងការបន្តការវិនិច្ឆ័យលើជនជាប់ចោទចំពោះបទឧក្រិដ្ឋជាតិ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក។

ធ្វើជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០

ចៅក្រម **និល ណុន**

**ប្រធាន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម **យ៉ា សុខន**

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម **ធូ មណី**